ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
MINISTRY OF ECONOMY AND FINANCE

លេខ ១៥
ឆ្នាំ២០២៣

# ព្រឹត្តិបត្រ

## កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# បុព្វកថា

បច្ច័យ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានក្លាយជាសមិទ្ធផលគួរជាទីមោទនៈសម្រាប់សង្គមជាតិ ក្នុងក្ដីសង្ឃឹម និងភាពជឿជាក់យ៉ាងមុតមាំក្នុងការបន្តរក្សាបាននូវស្ថិរភាព និងកំណើនសេដ្ឋកិច្ចរីកចម្រើនលើគ្រប់វិស័យ។ កម្ពុជាបានរួចផុតពីបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ ព្រមទាំងរក្សាភាពមាំមួន ភាពជាម្ចាស់ និងតួនាទីរបស់រដ្ឋក្នុងការកាត់បន្ថយការពឹងពាក់លើប្រាក់កម្ចីពីក្រៅប្រទេស។ រាជរដ្ឋាភិបាល អាណត្តិទី ៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** មានទស្សនវិស័យបន្តបេសកកម្មដ៏ឧត្តុងឧត្តមក្នុងការពន្លឿនកិច្ចអភិវឌ្ឍជំរុញការងារកែទម្រង់ និងកសាងជាតិមាតុភូមិឆ្ពោះទៅរកអនាគតដ៏រុងរឿងស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។ ជាក់ស្ដែងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល បានបន្តការពង្រឹងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដែលមានស្ថិរភាពរឹងមាំ ធន់នឹងវិបត្តិ និងទ្រទ្រង់ដល់កំណើនខ្ពស់ ប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលប្ដេជ្ញាបន្តបង្កើនភាពស៊ីជម្រៅ និងពង្រឹងភាពធន់ហិរញ្ញវត្ថុ ព្រមទាំងការពង្រីកបរិយាប័ន្នហិរញ្ញវត្ថុរួមបញ្ចូលនូវការរៀបចំ និងការកែលម្អក្របខ័ណ្ឌនិងយន្តការហិរញ្ញប្បទាន សំដៅរួមចំណែកជំរុញសកម្មភាពសេដ្ឋកិច្ច ជំរុញវិនិយោគ និងជំរុញធ្វើបរិវត្តកម្មឌីជីថល។

ជាមួយឆន្ទៈដ៏មុតស្រួចឥតរាថយរបស់រាជរដ្ឋាភិបាល,ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រេចបានជាសារវន្តនូវដំណាក់កាលទី ១ ដំណាក់កាលទី ២ និងដំណាក់កាលទី ៣ ប្រកបដោយផ្លែផ្កាជាផលវិជ្ជមាន និងជាឧត្តមប្រយោជន៍ដល់ប្រទេសជាតិទាំងមូល។ សមិទ្ធផលដ៏ត្រចះត្រចង់រយៈពេល២០ឆ្នាំកន្លងមក ពិតជាមិនអាចកាត់ផ្ដាច់បានពីការចូលរួមរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធក្នុងការដឹកនាំ និងអនុវត្តការងារកែទម្រង់ប្រកបដោយស្មារតីសហការល្អ និងការទទួលខុសត្រូវខ្ពស់។ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដ៏ខ្ពង់ខ្ពស់បំផុតដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដោយបានបោះជំហានឈានចូលមកដល់ដំណាក់កាលយុទ្ធសាស្ត្រកម្រិតខ្ពស់សំដៅដល់ការពង្រឹងប្រសិទ្ធភាព គុណភាព និងការទទួលខុសត្រូវលើលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នសាធារណៈ និងមន្ត្រីរាជការក្នុងក្របខ័ណ្ឌរាជរដ្ឋាភិបាលទាំងមូល។

ក្នុងនាមជាស្ថាប័ននិម្មាបនករ, គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ដែលមានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ជាសេនាធិការ នៅតែបន្តកិច្ចខិតខំប្រឹងប្រែងសម្របសម្រួល និងជំរុញការងារកែទម្រង់ក្នុងគោលដៅរួមគ្នា កសាងភាពរឹងមាំនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ដែលកំពុងអនុវត្តដំណាក់កាលទី ៤ "គណនេយ្យភាពសមិទ្ធកម្ម" ឆ្នាំ២០២៣ ដល់ ឆ្នាំ២០២៧។ នៅដំណាក់កាលទី ៤ នេះ នឹងមានការកែទម្រង់សមាសធាតុគន្លឹះៗ នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ដោយសម្រេចឱ្យបាននូវគោលដៅពង្រឹង និងពង្រីកប្រព័ន្ធគណនេយ្យសាធារណៈ ប្រព័ន្ធសវនកម្មនិងអធិការកិច្ចហិរញ្ញវត្ថុ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) យុទ្ធសាស្ត្រកែទម្រង់ និងច្បាប់គន្លឹះសំខាន់ៗ ដើម្បីជាមូលដ្ឋានគ្រឹះ នៃ "ប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម"។

ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងរូបខ្ញុំផ្ទាល់ សូមធ្វើការវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន, អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, កិច្ចសហប្រតិបត្តិការភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ និងជាពិសេសអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) ដែលបានខិតខំបំពេញមុខងាររបស់ខ្លួនជាសេនាធិការជូនគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.) ទាំងការងារដឹកនាំ សម្របសម្រួល គាំទ្រ ផ្សព្វផ្សាយ ត្រួតពិនិត្យ ព្រមទាំងវាយតម្លៃ ប្រកបដោយស្មារតីបុរេសកម្ម សកម្ម និងអន្តរសកម្ម៕

ថ្ងៃ ព្រហស្បតិ៍ ៧ កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# អារម្ភកថា

ឆ្លងកាត់វិថី នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេល ៣ ដំណាក់កាល កន្លងមក កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្រេចនូវសមិទ្ធផលការងារជាច្រើន ក្នុងនោះក៏មានដូចជាការរួមចំណែកដោះស្រាយនូវវិបត្តិ និងគ្រោះមហន្តរាយជាយថាហេតុនានា ក៏ដូចជាការរក្សាបាននូវសុខសន្តិភាពនិងស្ថិរភាពសេដ្ឋកិច្ចជាតិ ជូនដល់ប្រជាពលរដ្ឋកម្ពុជា។ កម្ពុជាក៏បាននិងកំពុងតែពង្រឹងធនធានមនុស្សកម្ពុជាឱ្យកាន់តែខ្លាំងខ្លាជាងមុនបន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្មទី ៤ ឌីជីថលភាវូបនីយកម្ម និងបរិវត្តកម្មឌីជីថល ដូចនេះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការងារកែទម្រង់ស្នូលមួយរបស់រាជរដ្ឋាភិបាលក្នុងការរក្សាឱ្យបាននូវចំណូលថវិកាជាតិ សម្រាប់គាំទ្រលើការងារទាំងនេះ និងការងារអាទិភាពក្នុងការអភិវឌ្ឍជាតិដ៏ទៃទៀត។ បច្ចុប្បន្នកម្ពុជាកំពុងស្ថិតលើជំហរមួយដ៏ត្រឹមត្រូវក្នុងការឆ្ពោះទៅរកការកសាងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ។ សមិទ្ធផលគួរជាទីមោទនៈមួយរបស់ប្រទេសជាតិ និងប្រជាជនកម្ពុជាទាំងមូល គឺជាការប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប និងការបន្តពង្រឹងអភិវឌ្ឍន៍ខ្លួនឱ្យសម្រេចនូវចក្ខុវិស័យវែងឆ្ងាយ គឺជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០។

ការឈានចូលដំណាក់កាលទី ៤ "គណនេយ្យភាពសមិទ្ធកម្ម" ដែលបានប្រកាសដាក់ឱ្យអនុវត្តនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៣ គឺជាដំណាក់កាលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលនឹងពង្រឹងការទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នផ្អែកលើលទ្ធផលការងារ ប្រសិទ្ធភាព និងគុណភាពដែលជាមូលដ្ឋានគ្រឹះក្នុងការសម្រេចឱ្យបាននូវប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្មដ៏រឹងមាំ ដើម្បីឈានកាន់តែខិតទៅជិតគោលបំណងចុងក្រោយ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ទន្ទឹមនេះ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងទស្សនៈវិស័យវែងឆ្ងាយរបស់រាជរដ្ឋាភិបាលថ្មី នីតិកាលទី ៧ នៃរដ្ឋសភា ដែលមាន **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ជាប្រមុខ និងបានយកចិត្តទុកដាក់និងជំរុញលើគ្រប់វិស័យ ដោយផ្តោតអាទិភាពលើការកែទម្រង់អភិបាលកិច្ច សំដៅពង្រឹងស្ថាប័នសាធារណៈ ដែលមានសមត្ថភាពខ្ពស់ ខ្លាំង វៃឆ្លាត និងស្អាតស្អំ រួមបញ្ចូលផងដែរនូវការពង្រឹងគោលការណ៍នីតិរដ្ឋ និងការពង្រឹងយុត្តិធម៌ក្នុងសង្គម ព្រមទាំងការបង្កើនប្រសិទ្ធភាពនិងការលើកកម្ពស់គុណភាពសេវាសាធារណៈ, ការពង្រឹងបរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដែលមានស្ថិរភាពរឹងមាំធន់នឹងវិបត្តិ និងទ្រទ្រង់ដល់កំណើនខ្ពស់ ប្រកបដោយចីរភាព បរិយាប័ន្ន និងសមធម៌។

ព្រឹត្តិបត្រ លេខ ១៥ នេះ ជាសក្ខីកម្មអំពីវឌ្ឍនភាព នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបានចងក្រងនូវបច្ចុប្បន្នភាពនៃព្រឹត្តិការណ៍ អត្ថបទ សុន្ទរកថា និងទស្សនៈនិងមតិរបស់ថ្នាក់ដឹកនាំ ដែលពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលមានតម្លៃជាសារវន្តអាចផ្តល់ជាធាតុចូលបន្ថែមដល់មន្ត្រីរាជការ សាធារណជនយកទៅសិក្សានិងឈ្វេងយល់បន្ថែមអំពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល៕

ថ្ងៃ សុក្រ ៨ កើត ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០២៤

**រដ្ឋលេខាធិការ**

**និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រស់_សីលវ៉ា**

# មាតិកានុក្រម

## ១ ព្រឹត្តិការណ៍


សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៣ ១

កិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយដៃគូអភិវឌ្ឍន៍ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ប្រចាំឆមាសទី ១ ឆ្នាំ២០២៣ ៥

ទស្សនកិច្ចសិក្សាស្តីពី "ការបើកចំហរព័ត៌មានថវិកា និងការអនុវត្តថវិកាសមិទ្ធកម្មនៅសាធារណរដ្ឋឥណ្ឌូនេស៊ី" ១១

សិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនិងការចែករំលែកបទពិសោធន៍ស្តីពីការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្ស ១៧


## ២ ទស្សនៈ


២១ ការអង្កេតលើការបើកចំហរថវិការបស់កម្ពុជាឆ្នាំ២០២៣

២៧ សញ្ញាណទូទៅនៃការវាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈ (Public Investment Management Assessment-PIMA) ដោយរួមបញ្ចូលការវាយតម្លៃពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ(Climate-PIMA ឬ C-PIMA)

៣៣ បច្ចេកវិទ្យាហិរញ្ញវត្ថុដើម្បីសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក

៤១ បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជាពីការស្ទុះងើបសេដ្ឋកិច្ចឡើងវិញឆ្ពោះទៅរកកំណែទម្រង់

## ៣ សុន្ទរកថា

សុន្ទរកថារបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣ក្រោមប្រធានបទ «ចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ទៀត៖ ការកំណត់មាគ៌ាសម្រាប់វិបុលភាពប្រកបដោយភាពធន់និរន្តរភាព និងបរិយាប័ន្ន» ៤៥

## ៤ ទស្សនៈ និងមតិ

៥១ សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ថ្លែងក្នុងពិធីបើកការដ្ឋានសាងសង់ចំណតផែកុងតឺន័រទឹកជ្រៅជំហានទី ១

៥៣ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ថ្លែងក្នុងពីធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ៣

៥៥ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ថ្លែងក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តជម្ពូវណ្ណារាមក្បាលទន្សោង ស្ថិតក្នុងភូមិក្បាលទន្សោង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

៥៧ ឯកឧត្តម **សាយ សំអាល់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ថ្លែងក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជូនប្រជាពលរដ្ឋ ក្នុងភូមិព្រៃញាតិ ភូមិដូង ភូមិផ្លូវដំរី ចំនួន ១,៧៧២ ក្បាលដី ក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ

៥៩ ឯកឧត្តម **ហែម វណ្ណឌី** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ថ្លែងក្នុងសិក្ខាសាលារយៈពេលពីរថ្ងៃស្ដីពី "នីតិវិធីនៃការអនុវត្តថវិកាសមិទ្ធកម្ម"ដែលជាជំហានថ្មីមួយក្នុងការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់សេវាសាធារណៈរបស់ខ្លួន

# ផ្នែកទី ១

# ព្រឹត្តិការណ៍


កិច្ចប្រជុំ
គណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ជាមួយដៃគូអភិវឌ្ឍន៍ស្តីពីការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤
ប្រចាំឆមាសទី ១ ឆ្នាំ២០២៣
ទស្សនកិច្ចសិក្សាស្តីពី
"ការបើកចំហរព័ត៌មានថវិកា និងការអនុវត្តថវិកាសមិទ្ធកម្មនៅសាធារណៈរដ្ឋឥណ្ឌូនេស៊ី"
សិក្ខាសាលាផ្សព្វផ្សាយ
លិខិតបទដ្ឋានគតិយុត្តនិងការចែករំលែកបទពិសោធន៍ស្តីពីការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្ស
របស់មន្ត្រីសាធារណៈ
សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣



# សន្និសីទ ចក្ខុវិស័យ ប្រទេស កម្ពុជា ឆ្នាំ២០២៣








នា ព្រឹកថ្ងៃព្រហស្បតិ៍ ១១ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧ ត្រូវនឹងថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បាន អញ្ជើញចូលរួមបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៣ ដែលរៀបចំឡើងនៅសណ្ឋាគារសុខាភ្នំពេញ។ សន្និសីទនេះ គឺជាវេទិកាដ៏មានសារៈសំខាន់ ដែលប្រមូលផ្តុំអ្នកជំនាញ និងបើកកិច្ចពិភាក្សាលើប្រធានបទនានា ពាក់ព័ន្ធនឹងបញ្ហាសេដ្ឋកិច្ចនិងសង្គម ដើម្បីជាធាតុចូលសម្រាប់ដោះស្រាយបញ្ហាប្រឈម និងស្វែងរកកាលានុវត្តភាព សម្រាប់ជំរុញដល់ការអភិវឌ្ឍនៅកម្ពុជា។







សន្និសីទនេះបានធ្វើឡើងជារៀងរាល់ឆ្នាំ រយៈពេលជាង ១០ ឆ្នាំ មកហើយ។ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣ធ្វើឡើងក្រោមប្រធានបទ«ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ទៀត៖ ការកំណត់មាគ៌ាសម្រាប់វិបុលភាពប្រកបដោយភាពធន់ និរន្តរភាព និងបរិយាប័ន្ន»។ សន្និសីទដែលរៀបចំឡើយដោយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI ) នឹងបង្ហាញអំពីវឌ្ឍនភាពនៃការសិក្សាស្រាវជ្រាវដែលកំពុងបន្តនេះនិងធ្វើការវាយតម្លៃលើជម្រើសគោលនយោបាយដែលកើតចេញពីសេណារីយ៉ូនាពេលអនាគតប្រកបដោយព័ត៌មានគ្រប់ជ្រុងជ្រោយ។កម្ពុជាបានកំណត់គោលដៅប្រកបដោយមហិច្ឆិតាក្នុងការប្រែក្លាយទៅជាប្រទេស ដែលមានចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសមានសេដ្ឋកិច្ចជឿនលឿននៅឆ្នាំ២០៥០។ដើម្បីស្វែងរកមាគ៌ាឆ្ពោះទៅមុខវិទ្យាស្ថាន CDRI បានផ្តួចផ្តើមការស្រាវជ្រាវយ៉ាងទូលំទូលាយមួយ ដើម្បីរួមចំណែកដល់ចក្ខុវិស័យនេះ។ សន្និសីទ ឆ្នាំ២០២៣ នេះ ដើរតួជាវេទិកាសំខាន់មួយ សម្រាប់ថ្នាក់ដឹកនាំជាង ៥០០ នាក់ រួមទាំងមន្ត្រីរាជការ អ្នកសិក្សាស្រាវជ្រាវ និងអ្នកជំនាញការជាតិនិងអន្តរជាតិ មករួមគ្នាដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗរបស់កម្ពុជា។ សន្និសីទ ឆ្នាំ២០២៣ នេះមានក្រុមពិភាក្សាសំខាន់ៗ ចំនួន ៣ វគ្គ ដែលវគ្គពិភាក្សានីមួយៗ ត្រូវបានរៀបចំឡើងដោយផ្តោតលើបញ្ហាសំខាន់ៗ អំពីទស្សនវិស័យសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា អាទិភាពនៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពនិងសក្តានុពលក្នុងការដកស្រង់បទពិសោធន៍ដើម្បីធ្វើឱ្យមានការរីកចម្រើនតាមគន្លងអភិវឌ្ឍន៍របស់ប្រទេសកម្ពុជា។កិច្ចពិភាក្សានីមួយៗមានគោលបំណងផ្តល់នូវការយល់ដឹងជាក់ស្តែងជំរុញឱ្យមានកិច្ចសន្ទនាស៊ីជម្រៅនិងផ្តល់នូវការយល់ដឹងទូលំទូលាយ អំពីទិដ្ឋភាពនៃការអភិវឌ្ឍរបស់ប្រទេសកម្ពុជា។ តាមរយៈសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៣ នេះ វិទ្យាស្ថាន CDRI បន្តការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការប្រមូលផ្តុំមេដឹកនាំ ដែលមានឥទ្ធិពលបំផុតពីប្រទេសកម្ពុជាអាស៊ីអាគ្នេយ៍។ល។ ដើម្បីជម្នះបញ្ហាប្រឈម និងយល់ដឹងពីចក្ខុវិស័យរបស់ប្រទេសកម្ពុជា ឆ្នាំ២០៣០ និងចក្ខុវិស័យ ឆ្នាំ២០៥០៕

រៀបចំអត្ថបទដោយ៖ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.

កិច្ចប្រជុំ

# គណៈកម្មាធិការ កែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ

## ជាមួយដៃគូអភិវឌ្ឍន៍ស្តីពីការត្រួតពិនិត្យ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤

**ប្រចាំឆមាសទី ១ ឆ្នាំ២០២៣**



នាព្រឹកថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០២៣, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (គ.ហ.ស.)បានដឹកនាំកិច្ចប្រជុំគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយដៃគូអភិវឌ្ឍន៍ ដើម្បីពិភាក្សាលើ "ការត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ប្រចាំឆមាសទី ១ ឆ្នាំ២០២៣"ដោយមានការអញ្ជើញចូលរួមពីសំណាក់ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំនិងសមាជិកក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រសួង ស្ថាប័ន, តំណាងដៃគូអភិវឌ្ឍន៍, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្តទាំង ២៥ និងតំណាងអង្គការមិនមែនរដ្ឋាភិបាល។

ផ្អែកតាមរបាយការណ៍វឌ្ឍនភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ៤ ប្រចាំឆមាសទី ១ ឆ្នាំ២០២៣, ការអនុវត្តការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈបានសម្រេចនូវសមិទ្ធកម្មគន្លឹះជាបណ្តើរៗ ក្នុងនោះរួមមានភាពជឿទុកចិត្តបាននៃថវិកាដែលជាកាតាលីករដ៏សំខាន់ក្នុងការរក្សាបាននូវស្ថិរភាពសេដ្ឋកិច្ច ក៏ដូចជាកំណើនម៉ាក្រូសេដ្ឋកិច្ច ទោះបីជាកម្ពុជាបានជួបប្រទះនូវវិបត្តិសកលនានា ក្នុងពេលកន្លងមកក៏ដោយ។ ជាក់ស្តែង ទោះបីជាការប្រមូលចំណូលថវិកាជាតិក្នុងរយៈពេល ៦ ខែ នៃឆ្នាំ២០២៣ នេះ មានភាពថមថយបន្តិច បើធៀបនឹងរយៈពេលដូចគ្នានៅឆ្នាំមុន,តែការប្រមូលចំណូលជារួមនឹងនៅតែស្ថិតក្នុងស្ថានភាពអាចគ្រប់គ្រងបាន។ចំពោះការអនុវត្តចំណាយថវិកាជាតិគិតត្រឹមឆមាសទី ១ សម្រេចបានទាបជាងផែនការបន្តិច ប៉ុន្តែតាមការប៉ាន់ស្មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការអនុវត្តចំណាយនៅដំណាច់ឆ្នាំនឹងសម្រេចបានតាមការគ្រោងទុក។ជាមួយនឹងវឌ្ឍនភាពល្អប្រសើរដែលសម្រេចបានកន្លងមក,ការរៀបចំលិខិតបទដ្ឋានគតិយុត្តនៅតែដើរតួនាទីសំខាន់ក្នុងការបន្តនិរន្តរភាពកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ក្នុងស្មារតីនេះឯកសារគោលស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ,ឯកសារគោលស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិ-





រដ្ឋ, គោលការណ៍ណែនាំរួមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អនុក្រឹត្យស្តីពីការកំណត់គុណវុឌ្ឍិវិជ្ជាជីវៈមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំ និងគ្រោងដាក់ឱ្យអនុវត្តក្នុងពេលឆាប់ៗខាងមុខនេះ ដើម្បីជំរុញប្រសិទ្ធភាពការងារថែមមួយកម្រិតទៀត។ លើសពីនេះប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(FMIS),ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ (SARMIS), និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (NRMIS) ត្រូវបានដាក់ឱ្យប្រើប្រាស់ ក៏ដូចជាពង្រីកការប្រើប្រាស់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេស។ទោះជាយ៉ាងនេះក្តីក្នុងស្ថានភាពអន្តរកាលនៃការឆ្ពោះទៅរកការប្រើប្រាស់ប្រព័ន្ធពេញលេញរបស់ក្រសួងស្ថាប័នមួយចំនួនដែលបានជួបប្រទះបញ្ហាប្រឈមខ្លះៗក្នុងការអនុវត្តដែលទាមទារឱ្យមានការពង្រឹងគុណភាពប្រព័ន្ធ និងការសម្រួលដល់ការកត់ត្រាក្នុងប្រព័ន្ធជាបន្តបន្ទាប់។ ទន្ទឹមនេះ សមត្ថភាពក្រសួង ស្ថាប័ន ក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាកិច្ចការអាទិភាពដែលតែងតែត្រូវបានយកចិត្តទុកដាក់ និងបន្តការពង្រឹងបន្ថែម។ ម៉្យាងទៀត នៅក្នុងជំហានដំបូងនៃការអនុវត្តថវិកាព័ត៌មានសមិទ្ធកម្មក្រសួងស្ថាប័នគឺជាតួអង្គសំខាន់ដែលត្រូវបានលើកទឹកចិត្ត

និងជំរុញឱ្យមានការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម តាមរយៈការណែនាំបណ្តុះបណ្តាល និងចែករំលែកបទពិសោធន៍នានា មុននឹងឆ្ពោះទៅរកការវាយតម្លៃលើសមិទ្ធកម្មពេញលេញនៅឆ្នាំបន្ទាប់។ តំណាងដៃគូអភិវឌ្ឍន៍ និងអង្គការក្រៅរដ្ឋាភិបាល បានអបអរសាទរដល់រាជរដ្ឋាភិបាលដែលសម្រេចបានសមិទ្ធផលល្អប្រសើរក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ជាមួយគ្នានេះ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលបានចូលរួមផ្តល់នូវមតិយោបល់ និងសំណើមួយចំនួនសម្រាប់ការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងឆ្លើយតបទៅនឹងស្ថានភាពសេដ្ឋកិច្ចសកលរួមមាន៖ការធ្វើសមាហរណកម្មប្រព័ន្ធបច្ចេកវិទ្យារបស់រាជរដ្ឋាភិបាល,ថវិកាឆ្លើយតបនឹងយេនឌ័រ,ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមគោលការណ៍បៃតង និងការលើកកម្ពស់តម្លាភាពថវិកា។ល។

ជាទីបញ្ចប់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានថ្លែងអំណរគុណ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងកន្លងមក របស់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងស្ថាប័នរហូតសម្រេចបានសមិទ្ធផលនៅឆមាសទី ១ ឆ្នាំ២០២៣ នេះ ព្រមទាំងជានាបាននូវសន្ទុះចលនការ នៃការកែទម្រង់សម្រាប់រាជរដ្ឋាភិបាលអាណត្តិថ្មី នីតិកាលទី ៧ នៃរដ្ឋសភា។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ក៏បានស្នើគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន បន្តជំរុញការអនុវត្តផែនការសកម្មភាពរួម ដំណាក់កាលទី ៤ នៅត្រីមាសបន្ទាប់ ដើម្បីសម្រេចតាមគោលដៅដែលបានគ្រោងទុក៕

រៀបចំអត្ថបទដោយ៖ ផ្នែកចំណូលសារពើពន្ធ នៃ អ.គ.ហ.









ទស្សនកិច្ចសិក្សាស្ដីពី

# “ការបើកចំហរព័ត៌មានថវិកា និងការអនុវត្តថវិកាសមិទ្ធកម្មនៅសាធារណរដ្ឋឥណ្ឌូនេស៊ី”





អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) តំណាងដោយ ឯកឧត្តម **មាស សុខសេនសាន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាអគ្គលេខាធិការរងនៃ អ.គ.ហ. បានដឹកនាំគណៈប្រតិភូកម្ពុជាទៅចូលរួមដំណើរទស្សនកិច្ចសិក្សានៅសាធារណរដ្ឋឥណ្ឌូនេស៊ី ចាប់ពីថ្ងៃទី២ ដល់ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣។ ដំណើរទស្សនកិច្ចសិក្សានេះ មានការអញ្ជើញចូលរួមពីតំណាង នៃអគ្គនាយកដ្ឋានថវិកា, អគ្គនាយកដ្ឋានរតនាគារជាតិ, អគ្គនាយកដ្ឋានគោលនយោបាយ, អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ, ក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, អាជ្ញាធរសវនកម្មជាតិ, និងមន្ត្រីជំនាញនៃ អ.គ.ហ. សរុបចំនួន ២៨ រូប។ គោលបំណងនៃដំណើរទស្សនកិច្ចសិក្សា៖ (១) សិក្សាពីឧត្តមានុវត្តន៍នៃការពង្រឹងតម្លាភាពថវិកា និងការបើកចំហថវិកា (២) ស្វែងយល់ពីបទពិសោធន៍ក្នុងការអនុវត្តថវិកាសមិទ្ធកម្មរបស់ប្រទេសឥណ្ឌូនេស៊ី។

# ការចែករំលែកបទពិសោធន៍របស់ប្រទេសឥណ្ឌូនេស៊ី

## ១. ការបើកចំហថវិកា និងកិច្ចសហប្រតិបត្តិការជាមួយអង្គការសង្គមស៊ីវិល

តាមបទពិសោធន៍របស់ប្រទេសឥណ្ឌូនេស៊ី, មានកត្តាសំខាន់ៗ ចំនួន ៥ រួមចំណែកក្នុងការទទួលបានពិន្ទុល្អលើការវាយតម្លៃសន្ទស្សន៍នៃការបើកចំហថវិកា (Open Budget Index-OBI) ដែលកត្តាទាំងនោះរួមមាន៖

១).ការអនុវត្តច្បាប់ដើម្បីឆ្ពោះទៅសម្រេចគោលបំណងនៃការលើកកម្ពស់តម្លាភាពថវិកានិងការបើកចំហថវិកា៖ (១) ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ (២) ច្បាប់ស្តីពីការបើកចំហព័ត៌មានសាធារណៈ និង (៣) ច្បាប់ស្តីពីបូរណភាពទិន្នន័យជាតិ។

២).ការប្រើប្រាស់ការអង្កេតលើការបើកចំហថវិកា (Open Budget Survey - OBS) ជាមាត្រដ្ឋានគោល (Benchmark) ដើម្បីឱ្យឯកសារថវិកាមានព័ត៌មាន និងខ្លឹមសារគ្រប់ជ្រុងជ្រោយ, ផ្សព្វផ្សាយបានទាន់ពេលវេលា និងមានការចូលរួមប្រកបដោយបរិយាប័ន្ន។

៣).ការអភិវឌ្ឍនិងប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Integrated Financial Management Information System-IFMIS) ដើម្បីសម្រួលដល់ការកត់ត្រា, ការរាយការណ៍ប្រតិបត្តិការថវិកា និងការផលិតរបាយការណ៍ ដែលបង្កភាពងាយស្រួលក្នុងការរៀបចំឯកសារថវិកានានា និងផ្សព្វផ្សាយបានទាន់ពេលវេលា។

៤).ការសម្របសម្រួលផ្ទាល់ជាមួយអង្គការសង្គមស៊ីវិលដើម្បីលើកកម្ពស់ការចែករំលែកនិងផ្លាស់ប្តូរព័ត៌មាន (Mutual Understanding) តាមរយៈការសម្របសម្រួលផ្តល់ឯកសារ និងការបំភ្លឺនានា ពាក់ព័ន្ធនឹងការដាក់ពិន្ទុ OBS។

៥).ការកែទម្រង់វិធាន នីតិវិធី និងកិច្ចប្រតិបត្តិការរដ្ឋបាលសាធារណៈ (Bureaucratic Reform)៖ ការលើកកម្ពស់តម្លាភាពថវិកា និងការបើកចំហថវិកា គឺជាចំណែកមួយនៃការពង្រឹងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

## ដ្យាក្រាមក្របខ័ណ្ឌសមាសធាតុទាំង ៥ សម្រាប់ការលើកកម្ពស់តម្លាភាព និងការបើកចំហថវិកា










## ២. ការអនុវត្តថវិកាសមិទ្ធកម្ម និងមុខងារនៃប្រព័ន្ធ IFMIS

ច្បាប់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឥណ្ឌូនេស៊ីបានកំណត់ពីតួនាទីនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយផ្តល់សិទ្ធិអំណាចជូនក្រសួង ស្ថាប័នក្នុងការបញ្ជាចំណាយ រីឯក្រសួងហិរញ្ញវត្ថុវិញដើរតួនាទីជាគណនេយ្យករសាធារណៈ។ មុខងារត្រួតពិនិត្យថវិកា (Budget Control) ត្រូវបានអនុវត្តដោយក្រសួងហិរញ្ញវត្ថុ ក្នុងន័យផ្ទៀងផ្ទាត់ពី Fund Availability និងភាពត្រឹមត្រូវនៃគណនី។ ការរៀបចំគម្រោងថវិការបស់រដ្ឋាភិបាលឥណ្ឌូនេស៊ី ត្រូវបានផ្តោតលើសសរស្តម្ភសំខាន់ៗ ចំនួន ៣ គឺ (១) ការធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាវិនិយោគ (Unified Budget),(២)ការតម្រឹមជាមួយនឹងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម(Medium-Term Expenditure Framework), និង (៣) ការគ្រោងថវិកាផ្សារភ្ជាប់ទៅនឹងសមិទ្ធកម្ម។ ក្នុងនោះ, កិច្ចព្រមព្រៀងសមិទ្ធកម្ម និងប្លង់គណនីគឺជាឧបករណ៍ចម្បងក្នុងការអនុវត្តសសរស្តម្ភទាំង ៣ ខាងលើ។ រដ្ឋាភិបាលឥណ្ឌូនេស៊ីអនុវត្តកិច្ចព្រមព្រៀងសមិទ្ធកម្ម រវាងប្រធានាធិបតេយ្យ និងរដ្ឋមន្ត្រីក្រសួង ស្ថាប័ន, រវាងរដ្ឋមន្ត្រីក្រសួង ស្ថាប័ន និងប្រធានកម្មវិធី, និងរវាងប្រធានកម្មវិធីនិងប្រធានគម្រោង។ កញ្ចប់ថវិកា ដែលបានទទួលការអនុម័តរួចនឹងត្រូវអនុវត្តទាំងស្រុងតាមប្រព័ន្ធ IFMIS។



កម្មវិធី និងគម្រោងថវិការបស់ក្រសួង ស្ថាប័ននីមួយៗ សុទ្ធសឹងមានលេខកូដប្លង់គណនីដែលមានវិធីអានរៀងៗខ្លួនអាស្រ័យទៅចំណាត់ថ្នាក់ថវិកា។ លេខកូដប្លង់គណនីនេះត្រូវបានបែងចែកជា ២ ប្រភេទ គឺ (១) Summary Account/ Mother Account និង (២) Real Account/Child Account។ ផ្អែកលើទិន្នន័យហិរញ្ញវត្ថុ និងសមិទ្ធកម្មក្នុងប្រព័ន្ធ IFMIS, ក្រសួងហិរញ្ញវត្ថុឥណ្ឌូនេស៊ីអនុវត្តការត្រួតពិនិត្យ និងវាយតម្លៃថវិកាក្នុងគោលបំណង (១) Prove & Improve ការរៀបចំសូចនាករសមិទ្ធកម្មនិងកំណត់នូវបញ្ហាប្រឈមនៃការអនុវត្ត (២) Revise/Hold/Block ការស្នើចំណាយរបស់ក្រសួង ស្ថាប័ន ដើម្បីតម្រឹមការអនុវត្តថវិកាឱ្យមានសង្គតិភាពជាមួយគម្រោង ថវិកា និង (៣) ការប្រើប្រាស់ជាមូលដ្ឋានសម្រាប់ការវិភាជន៍ថវិកាឆ្នាំបន្ទាប់៕

រៀបចំអត្ថបទដោយៈ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.



សិក្ខាសាលាផ្សព្វផ្សាយ

# លិខិតបទដ្ឋានគតិយុត្ត និង ការចែករំលែកបទពិសោធន៍ ស្តីពីការបើកផ្តល់ប្រាក់ អត្ថប្រយោជន៍របស់មន្ត្រី សាធារណៈដោយបង្វែរត្រង់ ចូលគណនីបៀវត្ស

របស់មន្ត្រីសាធារណៈ











ស្របតាមមាគ៌ា នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល,អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) បានសហការជាមួយនឹងអង្គភាពនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (កសហវ.) រៀបចំសិក្ខាសាលាផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត និងការចែករំលែកបទពិសោធន៍ស្តីពី "ការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈ" ដោយមានការអញ្ជើញចូលរួមពីអង្គភាពក្រោមឱវាទ កសហវ., គ្រប់ក្រសួង ស្ថាប័ន, រដ្ឋបាលរាជធានី ខេត្ត, មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគាររាជធានី ខេត្ត សរុបប្រមាណ ៤០០ នាក់។ សិក្ខាសាលានេះត្រូវបានរៀបចំឡើងក្នុងគោលបំណងពង្រឹងនិងពង្រីកប្រសិទ្ធភាពនៃការអនុវត្តការទូទាត់ត្រង់នូវបុព្វលាភ,លាភការ,ប្រាក់បំណាច់,ប្រាក់បេសកកម្ម,ប្រាក់សង្គមកិច្ចនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀតចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារ ប្រកបដោយតម្លាភាព និងគណនេយ្យភាព។ ជាកិច្ចចាប់ផ្តើម ឯកឧត្តម **ប៊ូ វង្សសុខា** បានថ្លែងសន្ទរកថាបើកសិក្ខាសាលាដោយបានលើកឡើងអំពីសារតានិងសមិទ្ធផលសំខាន់ៗនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាពិសេសបទពិសោធន៍ដ៏ល្អក្នុងការបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការតាមប្រព័ន្ធធនាគារនៅទូទាំងប្រទេសដែលត្រូវបានអនុវត្តតាំងពីឆ្នាំ២០០៨មកម្លេះ។ ទន្ទឹមនេះ ឯកឧត្តម ក៏បានកត់សម្គាល់អំពីសារតា និងវឌ្ឍនភាពនៃការអនុវត្តការបើកប្រាក់អត្ថប្រយោជន៍នានារបស់មន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារដែលកិច្ចការនេះមានគោលបំណងជំរុញ និងពង្រឹងការបើកប្រាក់ជូនមន្ត្រីសាធារណៈតាមប្រព័ន្ធធនាគារ និងលុបបំបាត់ទាំងស្រុងនូវការអនុវត្តការបើកផ្តល់សាច់ប្រាក់ផ្ទាល់។

ជាកិច្ចបន្ទាប់ អង្គសិក្ខាសាលាបានស្តាប់បទបង្ហាញរបស់អគ្គនាយកដ្ឋានរតនាគារជាតិអំពីបទដ្ឋានគតិយុត្តនិងនីតិវិធីលម្អិតក្នុងការបើកផ្តល់ប្រាក់អត្ថប្រយោជន៍របស់មន្ត្រីសាធារណៈ ដោយបង្វែរត្រង់ចូលគណនីបៀវត្សរបស់មន្ត្រីសាធារណៈ និងការធ្វើបទអន្តរាគមន៍ពីក្រសួង ស្ថាប័នគន្លឹះចំនួន៥រួមមាន៖ទីស្តីការគណៈរដ្ឋមន្ត្រី,ក្រសួងការពារជាតិ,ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់។ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាយ៉ាងផុសផុលក្នុងអង្គសិក្ខាសាលា គ្រប់ក្រសួង ស្ថាប័នបានអនុវត្តការបើកប្រាក់បៀវត្ស បុព្វលាភ, លាភការ, ប្រាក់បំណាច់, ប្រាក់សង្គមកិច្ចនិងប្រាក់ឧបត្ថម្ភផ្សេងៗតាមប្រព័ន្ធធនាគារជូនមន្ត្រីសាធារណៈរួចហើយលើកលែងតែក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃដែលមានរចនាសម្ព័ន្ធស្ថាប័នខុសពីក្រសួងស្ថាប័នស៊ីវិលដ៏ទៃទៀតទាំងការធានាជីវភាពរស់នៅជាក់ស្តែង និងកិច្ចការសម្ងាត់មួយចំនួនរបស់ស្ថាប័ន។ ដោយឡែក ចំពោះការបើកប្រាក់បេសកកម្មទាំងក្នុងនិងក្រៅប្រទេសតាមប្រព័ន្ធធនាគារនៅតាមក្រសួងស្ថាប័នភាគច្រើនហាក់មានបញ្ហាប្រឈមមួយចំនួនដែលត្រូវដាក់ចេញវិធានការដោះស្រាយ ទាំងក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផង និងក្រសួង ស្ថាប័នសាមីផង។ផ្អែកតាមលទ្ធផលនៃកិច្ចពិភាក្សាខាងលើអង្គសិក្ខាសាលាបានកំណត់ទិសដៅការងារបន្ទាប់ដូចជា(១)បន្តជំរុញក្រសួងស្ថាប័នបង្កើនអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញនិងមិនពេញលេញ ដែលអាចបើកផ្លូវដល់អង្គភាពថវិកាមានសិទ្ធិចុះហត្ថលេខាផ្ទាល់លើមុខសញ្ញាចំណាយនានាហើយបញ្ជូនមកមន្ត្រីត្រួតពិនិត្យថវិកាតែម្តងដោយមិនចាំបាច់ឆ្លងដល់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន។ ក្នុងន័យនេះ អង្គភាពថវិកាមានសិទ្ធិពេញលេញក្នុងការចាត់ចែងថវិការបស់ខ្លួនបានឆាប់រហ័ស និងទាន់ពេលវេលា។ (២) ស្របតាមទិសដៅនៃការកែទម្រង់ កសហវ. នឹងផ្ទេរមុខងារទាំងអស់ជូនមន្ត្រីត្រួតពិនិត្យថវិកានៅអមក្រសួង ស្ថាប័ន ដោយពុំចាំបាច់ឆ្លងនីតិវិធីដល់ថ្នាក់ដឹកនាំក្រសួង ស្ថាប័ន ឬ កសហវ. ទៀតឡើយ (លើកលែងតែចំណាយដែលមានហានិភ័យខ្ពស់)។កិច្ចការនេះបាននិងកំពុងអនុវត្តសាកល្បងនៅ កសហវ. និងក្រសួងបរិស្ថាន ដែលមានអង្គភាពថវិកាជាអាណាប័កផ្ទេរសិទ្ធិពេញលេញហើយគ្រោងនឹងដាក់អនុវត្តនៅគ្រប់ក្រសួង ស្ថាប័នជាបន្តបន្ទាប់យ៉ាងយូរត្រឹមឆ្នាំ២០២៥។ (៣)រតនាគាររាជធានី ខេត្ត ត្រូវបន្តផ្សព្វផ្សាយអនុក្រឹត្យ និងសារាចរណែនាំនេះដល់រដ្ឋបាលថ្នាក់ក្រោមដើម្បីជំរុញការអនុវត្តឱ្យបានគ្រប់ជ្រុងជ្រោយប្រកបដោយប្រសិទ្ធភាព។ (៤) កសហវ. ត្រូវផ្តល់ការគាំទ្រ ឬចែករំលែកបទពិសោធន៍តាមសំណើក្រសួង ស្ថាប័នក្នុងការកំណត់បញ្ហាប្រឈមនិងដោះស្រាយផ្អែកបច្ចេកទេសសំដៅជំរុញការអនុវត្តប្រកបដោយប្រសិទ្ធភាព៕

រៀបចំអត្ថបទដោយៈ ផ្នែកចំណូលសារពើពន្ធ នៃ អ.គ.ហ.


ការអង្កេតលើ
ការបើកចំហថវិកា
របស់កម្ពុជា ឆ្នាំ២០២៣


សញ្ញាណទូទៅនៃការវាយតម្លៃ
ការគ្រប់គ្រងការវិនិយោគសាធារណៈ
(Public Investment Management Assessment-PIMA)
ដោយរួមបញ្ចូលការវាយតម្លៃពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ


ដើម្បីសេដ្ឋកិច្ច
និងសង្គមឌីជីថល
កម្ពុជាដ៏រស់រវើក


ពីការស្ទុះងើប
សេដ្ឋកិច្ចឡើងវិញ
ឆ្ពោះទៅរកកំណែទម្រង់

# ផ្នែកទី ២

# អត្ថបទ

# ការអង្កេតលើ ការបើកចំហថវិកា របស់កម្ពុជា ឆ្នាំ២០២៣



តម្លាភាពថវិកានៅកម្ពុជាត្រូវបានវាយតម្លៃដោយសហគមន៍អន្តរជាតិថាមានភាពប្រសើរជាងមុន តាមរយៈការអង្កេតលើការបើកចំហថវិកា (Open Budget Survey - OBS) ដែលរៀបចំដោយអង្គការភាពជាដៃគូថវិកាអន្តរជាតិ (International Budget Partnership - IBP)។ ភាពប្រសើរឡើងនៃស្ថានភាពតម្លាភាពថវិកានៅកម្ពុជា បានរួមចំណែកដោយកត្តាជាច្រើន ដែលក្នុងនោះកត្តាចម្បងគឺការផ្សព្វផ្សាយឯកសារថវិកាបានទាន់ពេលវេលាជាមួយនឹងការពង្រឹងគុណភាពនៃឯកសារថវិកាឱ្យមានភាពគ្រប់ជ្រុងជ្រោយជាងមុន។ ជាក់ស្តែង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចាប់ផ្តើមផ្សព្វផ្សាយសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣ នៅលើគេហទំព័ររបស់ក្រសួងជាលើកដំបូង ដែលកន្លងមកក្រសួងធ្លាប់បានផ្សព្វផ្សាយត្រឹមតែខ្លឹមសារសង្ខេបប្រតិបត្តិនៃសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុប៉ុណ្ណោះ។ ក្រោមការសម្របសម្រួលរបស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (អ.គ.ហ.) កម្ពុជាបានចូលរួមការអង្កេតលើការបើកចំហថវិកា ដែលរៀបចំដោយអង្គការភាពជាដៃគូថវិកាអន្តរជាតិ និងប្រព្រឹត្តទៅជារៀងរាល់ ២ ឆ្នាំម្តង ចាប់ពីឆ្នាំ២០០៨ មក។ ការអង្កេតនេះ ចូលរួមដោយប្រទេសប្រមាណជាង ១០០ នៅជុំវិញពិភពលោក ហើយផ្តោតសំខាន់លើ ៣ ទិដ្ឋភាពរួមមាន៖ (១) តម្លាភាពថវិកា, (២) ការចូលរួមរបស់សាធារណជនក្នុងដំណើរការថវិកា និង (៣) ការត្រួតពិនិត្យថវិកា, ខណៈសន្ទស្សន៍នៃការអង្កេតលើការបើកចំហថវិកា (Open BudgetIndex-OBI)ផ្តោតតែលើទិដ្ឋភាពតម្លាភាពថវិកាប៉ុណ្ណោះដែលកម្ពុជាទទួលបានលទ្ធផលដូចខាងក្រោម៖



# ឯកសារដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃ

ការអង្កេត OBS ផ្តោតលើឯកសារគោលចំនួន ៨ ដែលបានបោះពុម្ពផ្សាយចាប់ពីថ្ងៃទី១ ខែមករា រហូតដល់ថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំដែលការអង្កេតប្រព្រឹត្តទៅ។ ឯកសារគោលសំខាន់ៗ ទាំង ៨ ដែលត្រូវបានប្រើប្រាស់សម្រាប់ការវាយតម្លៃការបើកចំហថវិកា រួមមាន៖ (១) ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុ ឬសារាចរណែនាំស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ(២)សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំរបស់រាជរដ្ឋាភិបាល (៣) ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលបានអនុម័ត (៤) សៀវភៅថវិកាសង្ខេបឬសៀវភៅថវិកាពលរដ្ឋ(៥)របាយការណ៍ក្នុងឆ្នាំ(របាយការណ៍ប្រតិបត្តិការហិរញ្ញវត្ថុរដ្ឋ, របាយការណ៍ស្ថិតិហិរញ្ញវត្ថុរដ្ឋាភិបាល, -ល-) (៦) របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១និងការវាយតម្លៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ (៧) ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋ ឬរបាយការណ៍ដំណាច់ឆ្នាំ និង (៨) របាយការណ៍សវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ឯកសារគោលសំខាន់ៗទាំង ៨ នេះ ត្រូវបានរៀបចំ និងផ្សព្វផ្សាយដោយអគ្គនាយកដ្ឋានពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាប័នកំពូលមួយចំនួននៃរាជរដ្ឋាភិបាល។ អគ្គនាយកដ្ឋាន ដែលដើរតួនាទីសំខាន់ក្នុងការរៀបចំនិងផ្សព្វផ្សាយឯកសារថវិការួមមានអគ្គនាយកដ្ឋានថវិកា,អគ្គនាយកដ្ឋានគោលនយោបាយ, អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ខណៈស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលមានដូចជាព្រឹទ្ធសភា រដ្ឋសភា និងអាជ្ញាធរសវនកម្មជាតិ ក៏មានតួនាទីសំខាន់ក្នុងការត្រួតពិនិត្យថវិកា និងការលើកកម្ពស់ការចូលរួមរបស់សាធារណជនក្នុងដំណើរការថវិកា។ រយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ កម្ពុជាមានវឌ្ឍនភាពល្អ ក្នុងការរៀបចំ និងផ្សព្វផ្សាយឯកសារថវិកាសំខាន់ៗ ដោយបានផ្លាស់ប្តូរពីការរៀបចំយឺតយ៉ាវ មករៀបចំបានទាន់ពេលវេលា ពីមិនបានផ្សព្វផ្សាយសម្រាប់ឯកសារមួយចំនួនមកផ្សព្វផ្សាយជាសាធារណៈ។ ជាក់ស្តែង វឌ្ឍនភាពក្នុងការរៀបចំឯកសារគោលទាំង ៨ មានបង្ហាញជូនក្នុងតារាងខាងក្រោម៖



## ការរៀបចំ និងផ្សព្វផ្សាយឯកសារគោលទាំង ៨

| ឯកសារគោលទាំង ៨ | ២០០៨ | ២០១០ | ២០១២ | ២០១៥ | ២០១៧ | ២០១៩ | ២០២១ | ២០២៣ |
|---|---|---|---|---|---|---|---|---|
| សារាចរណែនាំស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ | 🟡 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 | 🟡 | 🟢 | 🟢 | 🟢 |
| ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលបានអនុម័ត | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 | 🟢 |
| សៀវភៅថវិកាសង្ខេប ឬសៀវភៅថវិកាពលរដ្ឋ | 🚫 | 🚫 | 🚫 | 🟡 | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ក្នុងឆ្នាំ | 🟢 | 🟢 | 🟢 | 🟡 | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | 🟡 | 🟡 | 🟡 | 🟡 | 🟢 | 🟢 | 🟢 | 🟢 |
| របាយការណ៍ដំណាច់ឆ្នាំ | 🟢 | 🟢 | 🟢 | 🚫 | 🟡 | 🟢 | 🟢 | 🟢 |
| របាយការណ៍សវនកម្ម | 🟡 | 🟡 | 🟡 | 🚫 | 🟢 | 🟢 | 🟢 | 🟢 |

*សំគាល់៖* 🟢 ផ្សព្វផ្សាយជាសាធារណៈ 🟡 ផ្សព្វផ្សាយឃ៉ឹត ឬសម្រាប់ប្រើប្រាស់ផ្ទៃក្នុង 🚫 មិនបានផលិត



ថ្វីបើកម្ពុជាមានវឌ្ឍនភាពល្អក្នុងការរៀបចំ និងផ្សព្វផ្សាយឯកសារថវិកាសំខាន់ៗ បានទាន់ពេលវេលាក៏ពិតមែន យ៉ាងណាមិញខ្លឹមសារនៃឯកសារមួយចំនួន ហាក់មិនទាន់មានភាពគ្រប់ជ្រុងជ្រោយតាមតម្រូវការនៃ OBS នៅឡើយ ដែលកិច្ចការនេះទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមពីភាគីពាក់ព័ន្ធ ជាពិសេសគួរមានការយកចិត្តទុកដាក់បន្ថែមលើការរៀបចំសេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ ដោយសារ OBS មានតម្រូវការខ្ពស់ និងទាមទារនូវភាពគ្រប់ជ្រុងជ្រោយខ្លាំងលើឯកសារនេះ។ ពិន្ទុលម្អិតសម្រាប់ឯកសារនីមួយៗ សម្រាប់ការអង្កេត OBS ឆ្នាំ២០១៧, ឆ្នាំ២០១៩ និងឆ្នាំ២០២១ មានបង្ហាញជូនក្នុងតារាងខាងក្រោម៖



### ពិន្ទុលម្អិតសម្រាប់ឯកសារគោលទាំង ៨

| ឯកសារគោលទាំង ៨ | ២០០៨ | ២០១៩ | ២០២១ |
|---|---|---|---|
| សារាចរណែនាំស្តីពីការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ | ៥៦ | ៥៦ | ៣៣ |
| សេចក្តីព្រាងច្បាប់ថវិកាប្រចាំឆ្នាំ | សម្រាប់ប្រើប្រាស់ផ្ទៃក្នុង | ១៤ | ១៤ |
| ច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំដែលបានអនុម័ត | ៨៤ | ៨៤ | ៨៤ |
| សៀវភៅថវិកាសង្ខេប ឬសៀវភៅថវិកាពលរដ្ឋ | ៣៣ | ៣៣ | ៣៣ |
| របាយការណ៍ក្នុងឆ្នាំ | ៦៣ | ៦៧ | ៧៤ |
| របាយការណ៍ពាក់កណ្តាលឆ្នាំ | ៣៧ | ៤៨ | ៥៦ |
| របាយការណ៍ដំណាច់ឆ្នាំ | សម្រាប់ប្រើប្រាស់ផ្ទៃក្នុង | ៣៣ | ៤០ |
| របាយការណ៍សវនកម្ម | ៣៨ | ៤៣ | ៤៣ |



## ការកើនឡើងនៃសន្ទស្សន៍ការបើកចំហថវិកាកម្ពុជា ឆ្នាំ២០២៣ (លទ្ធផលរំពឹងទុក)

ពិន្ទុនៃការអង្កេតលើការបើកចំហថវិការបស់កម្ពុជា ក្នុងឆ្នាំ២០២៣ នេះ អាចនឹងមានការកើនឡើងជាងមុន ហើយការកើនឡើងនៃពិន្ទុនេះ គឺដោយសារកត្តាមួយចំនួន ដូចជា៖

- ការផ្សព្វផ្សាយឯកសារថវិកា ក៏ដូចជារបាយការណ៍ពាក់ព័ន្ធបានទាន់ពេលវេលា
- ការពង្រឹងគុណភាពនៃឯកសារថវិកា ឱ្យមានភាពគ្រប់ជ្រុងជ្រោយជាងមុន
- ការបង្កើតក្រុមការងារអង្កេតការបើកចំហព័ត៌មានថវិការបស់កម្ពុជា ដែលដឹកនាំដោយ អ.គ.ហ. និងមានសមាជិកចូលរួមដែលជាតំណាងមកពីអគ្គនាយកដ្ឋានពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មន្ត្រីបង្គោលបានចូលរួមសិក្ខាសាលាស្តីពីការពិនិត្យលើកម្រងសំណួរ OBS ដែលបានរៀបចំដោយអង្គការ IBP នៅទីក្រុងអ៊ីស្តង់ប៊ុល (Istanbul) ប្រទេសតួកគី (Turkey) ដើម្បីស្វែងយល់ពីនីតិវិធី និងការណែនាំក្នុងការពិនិត្យនិងផ្តល់យោបល់លើកម្រងសំណួរ
- ការជួយគាំទ្រពីអ្នកជំនាញការផ្នែកតម្លាភាពថវិកា(Technical Assistant)ដែលផ្តល់ដោយប្រតិភូតំណាងសហភាពអឺរ៉ុបប្រចាំកម្ពុជា (EU Delegation in Cambodia)។

## ការប្រៀបធៀបសន្ទស្សន៍នៃការបើកចំហថវិកាកម្ពុជា ជាមួយប្រទេសនានា ក្នុងសកលលោក

យោងតាមលទ្ធផលរំពឹងទុក ពិន្ទុសម្រាប់ការអង្កេតឆ្នាំ២០២៣ របស់កម្ពុជាអាចនឹងមានការកើនឡើងឈានដល់កម្រិតខ្ពស់ប្រៀបធៀបជាមួយប្រទេសនានានៅលើសកលលោកដែលមានការអនុវត្តល្អលើទិដ្ឋភាពតម្លាភាពថវិកា ដូចជាប្រទេសហុងគ្រី, ម៉ាឡេស៊ី និងអាហ្សង់ទីន ជាដើម។

**ការប្រៀបធៀបសន្ទស្សន៍នៃការបើកចំហថវិកា ឆ្នាំ២០២១**




ការកើនឡើងនៃពិន្ទុ OBS របស់កម្ពុជាបានឆ្លុះបញ្ចាំងពីឆន្ទៈរបស់រាជរដ្ឋាភិបាល និងភាគីពាក់ព័ន្ធក៏ដូចជាកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាខ្ពស់ដែលនាំឱ្យកម្ពុជាសម្រេចបានវឌ្ឍនភាពល្អ ទាំងការលើកកម្ពស់តម្លាភាពថវិកា និងការងារកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈទាំងមូល។ តម្លាភាពថវិកា នៅក្នុងបរិបទកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើរតួនាទីយ៉ាងសំខាន់ ក្នុងការរួមចំណែកសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ជាតិដោយសារតម្លាភាពបានជួយបង្កើនទំនុកចិត្តរបស់វិនិយោគិន និងជាធាតុចូលដល់តួអង្គអភិវឌ្ឍន៍ទាំងអស់ក្នុងការសម្រេចចិត្តនានា។

រៀបចំអត្ថបទដោយ៖ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.



សញ្ញាណទូទៅនៃការវាយតម្លៃ

# ការគ្រប់គ្រងការវិនិយោគសាធារណៈ

**(Public Investment Management Assessment - PIMA)**

## ដោយរួមបញ្ចូលការវាយតម្លៃពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ

(Climate-PIMA ឬ C-PIMA)

## ១. អ្វីជាការវាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈ (PIMA)

PIMA គឺជាវិធីសាស្ត្រវាយតម្លៃគ្រប់ជ្រុងជ្រោយមួយ ដែលត្រូវបានបង្កើតឡើងដោយ IMF ប្រើសម្រាប់វាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈ និងអភិបាលកិច្ចហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនៅគ្រប់ប្រទេស និងគ្រប់កម្រិតអភិវឌ្ឍន៍ (ទាំងប្រទេសអភិវឌ្ឍន៍ និងប្រទេសកំពុងអភិវឌ្ឍន៍) ដោយផ្តោតលើការវាយតម្លៃនីតិវិធី, ឧបករណ៍, ការធ្វើសេចក្តីសម្រេចចិត្ត និងការត្រួតពិនិត្យដំណើរការនានា នៃការគ្រប់គ្រងការវិនិយោគសាធារណៈ សំដៅផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធ និងសេវាជូនប្រជាពលរដ្ឋប្រកបដោយស័ក្តិសិទ្ធភាព, ប្រសិទ្ធភាព, តម្លាភាព, គណនេយ្យភាព និងមានចីរភាពក្នុងរយៈពេលវែង។

## ២. ប្រវត្តិនៃការបង្កើតក្របខ័ណ្ឌ PIMA

ក្របខ័ណ្ឌ PIMA ត្រូវបានបង្កើតឡើងនៅឆ្នាំ២០១៥ និងត្រូវបានពិនិត្យនិងកែសម្រួលនៅឆ្នាំ២០១៨។ ក្របខ័ណ្ឌ PIMA ឆ្នាំ២០១៨ បានគូសបញ្ជាក់ពីទិដ្ឋភាពគន្លឹះៗ នៃការថែទាំ លទ្ធកម្ម ការពិនិត្យមើលឡើងវិញដោយឯករាជ្យនៃគម្រោង និងបរិស្ថាននានា (ដូចជាក្របខ័ណ្ឌគតិយុត្តគ្រប់គ្រាន់ ប្រព័ន្ធព័ត៌មាន សមត្ថភាពបុគ្គលិក)។ បច្ចុប្បន្ននេះ, PIMA ត្រូវបានទទួលស្គាល់ជាអន្តរជាតិយ៉ាងទូលំទូលាយសម្រាប់ការវាយតម្លៃលម្អិត និងការប្រៀបធៀបការអនុវត្តរបស់ PIM។ គួរកត់សម្គាល់ផងដែរថា ចំណុចពិសេសនៃ PIMA គឺការប្រើប្រាស់វិធីសាស្ត្រវាយតម្លៃជាក់លាក់ និងទិដ្ឋភាពម៉ាក្រូហិរញ្ញវត្ថុ (Marco Fiscal) ដើម្បីធ្វើការវាយតម្លៃដ៏ល្អមួយ។ ក្រៅពី PIMA នេះ, ឃើញថា ក្របខ័ណ្ឌចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ក៏ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយផងដែរ ដោយបានបញ្ចូលនូវពិន្ទុច្បាស់លាស់នៃការអនុវត្ត PIM។ ជារួម លទ្ធផលវាយតម្លៃដោយប្រើ PIMA បានបង្ហាញថា PIM ស្ទើរគ្រប់ប្រទេសនៅមានចំណុចខ្វះខាត និងត្រូវការពង្រឹងនិងកែលម្អបន្ថែម។

## ៣. ទិដ្ឋភាពទូទៅនៃក្របខ័ណ្ឌ PIMA

PIMA ត្រូវបានផ្តោតសំខាន់លើការវាយតម្លៃលើទិដ្ឋភាពក្របខ័ណ្ឌស្ថាប័ន (Institutional Strength) និងប្រសិទ្ធភាពនៃការអនុវត្ត (Practices/Effectiveness) និងបែងចែកជា ៣ ដំណាក់កាលគន្លឹះ នៃវដ្តវិនិយោគសាធារណៈ។ ក្នុងនោះដំណាក់កាលទាំង ៣ និងសសរស្តម្ភ/ស្ថាប័ន (Institutions) ចំនួន ៥ ក្នុងដំណាក់កាលនីមួយៗ ត្រូវធ្វើការវាយតម្លៃដូចខាងក្រោម៖

*ដំណាក់កាលទី១៖* ការរៀបចំផែនការវិនិយោគប្រកបដោយចីរភាពក្នុងវិស័យសាធារណៈ (Planning Sustainable Investment Across the Public Sector)៖ ត្រូវការស្ថាប័ន ដែលធានានូវចីរភាពផ្នែកហិរញ្ញវត្ថុ, ការសម្របសម្រួលរវាងវិស័យ និងរវាងគ្រប់កម្រិតរដ្ឋបាល (រវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ) ប្រកបដោយស័ក្តិសិទ្ធភាព និងការវាយតម្លៃសំណើគម្រោង (Project Appraisal) យ៉ាងម៉ត់ចត់។ ក្នុងដំណាក់កាលនេះមានការវាយតម្លៃសសរស្តម្ភ/ស្ថាប័ន និងការអនុវត្តចំនួន ៥ រួមមាន៖ ១) គោលដៅ និងវិធានថវិកា (Fiscal Targets and Rules), ២) ការរៀបចំផែនការជាតិ និងតាមវិស័យ (National and Sectoral Planning), ៣) ការសម្របសម្រួលរវាងអង្គភាព (Coordination Between Entities), ៤) ការវាយតម្លៃសំណើគម្រោង (Project Appraisal), និង ៥) ជម្រើសហិរញ្ញប្បទានហេដ្ឋារចនាសម្ព័ន្ធ (Alternative Infrastructure Financing)។

*ដំណាក់កាលទី២៖* ការបែងចែកធនធានវិនិយោគទៅតាមវិស័យ និងគម្រោងត្រឹមត្រូវ (Allocating Investment to the Right Sectors and Projects)៖ ទាមទារឱ្យមានការរៀបចំផែនការរយៈពេលមធ្យម, ភាពគ្រប់ជ្រុងជ្រោយ និងស៊ីសង្វាក់គ្នា, និងល័ក្ខខ័ណ្ឌវិនិច្ឆ័យសត្យានុម័ត សម្រាប់ជ្រើសរើសគម្រោងនានា។ ក្នុងដំណាក់កាលនេះ មានការវាយតម្លៃសសរស្តម្ភ/ស្ថាប័ន និងការអនុវត្តចំនួន ៥ រួមមាន៖ ១) ការរៀបចំថវិកាពហុឆ្នាំ (Multi-Year Budgeting), ២) ភាពគ្រប់ជ្រុងជ្រោយ និងឯកត្តភាពនៃថវិកា (Budget Comprehensiveness and Unity), ៣) ការរៀបចំថវិកាសម្រាប់វិនិយោគ (Budgeting for Investment), ៤) ការរៀបចំមូលនិធិថែទាំ (Maintenance Funding) និង ៥) ការជ្រើសរើសគម្រោង (Project Selection)។

*ដំណាក់កាលទី៣៖* ការអនុវត្តគម្រោងវិនិយោគទាន់ពេល និងតាមទំហំថវិកា (Implementing Projects on Time and Budget)៖ ត្រូវការស្ថាប័ន ដែលធានាថាគម្រោងនឹងទទួលបានមូលនិធិគ្រប់គ្រាន់, ការត្រួតពិនិត្យប្រកបដោយតម្លាភាព និងគ្រប់គ្រងប្រកបដោយស័ក្តិសិទ្ធភាព។ ក្នុងដំណាក់កាលនេះ មានការវាយតម្លៃស្ថាប័ន និងការអនុវត្តចំនួន ៥ រួមមាន៖ ១) លទ្ធកម្ម (Procurement), ២) លទ្ធភាពនៃមូលនិធិ (Availability of Funding), ៣) ការគ្រប់គ្រង និងត្រួតពិនិត្យគម្រោង (Portfolio Management and Oversight), ៤) ការគ្រប់គ្រងការអនុវត្តគម្រោង (Management of Project Implementation) និង ៥) ការត្រួតពិនិត្យទ្រព្យសម្បត្តិសាធារណៈ (Monitoring of Public Assets)។

## ៤. ការវាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈ ដោយឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ (C-PIMA)

មកដល់បច្ចុប្បន្ននេះការវាយតម្លៃPIMAត្រូវបានធ្វើបច្ចុប្បន្នកម្មដោយបញ្ចូលនូវការវាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ(Climate-PIMA ឬហៅថា C-PIMA)។ បណ្តាប្រទេសនៅក្នុងកិច្ចព្រមព្រៀងប៉ារីស និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព(SDGs)បានបន្តប្តេជ្ញាចិត្តកំណត់គោលដៅ និងគោលនយោបាយកម្រិតការកើនឡើងនៃសីតុណ្ហភាពដោយសារការប្រែប្រួលអាកាសធាតុ។ ហេតុនេះ ការផ្លាស់ប្តូរឆ្ពោះទៅរកការវិនិយោគសាធារណៈបៃតង (Green Public Investment) នឹងជួយកាត់បន្ថយការរីកសាយភាយឧស្ម័នផ្ទះកញ្ចក់។ ទន្ទឹមនេះដែរ ការវិនិយោគសាធារណៈប្រកបដោយចីរភាពនឹងមានសារសំខាន់ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធសាធារណៈឱ្យកាន់តែមានភាពធន់ នៃសេដ្ឋកិច្ចចំពោះការប្រែប្រួលអាកាធាតុ និងគ្រោះមហន្តរាយនានា ជាយថាហេតុ។ ដើម្បីបំពេញចន្លោះខ្វះខាតនៃការវាយតម្លៃ PIMA កន្លងមក ឯកសារបច្ចុប្បន្នបានបង្ហាញពីម៉ូឌុលថ្មី នៃ PIMA ឬហៅថា Climate-PIMA ឬ C-PIMA ក្នុងគោលដៅជួយរដ្ឋាភិបាលកំណត់នូវការពង្រឹងស្ថាប័នវិនិយោគសាធារណៈ និងដំណើរការនានាប្រកបដោយសក្តានុពលដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ ដែលមានកាបូនទាប និងភាពធន់នៃបម្រែបម្រួលអាកាសធាតុ។ គួរបញ្ជាក់បន្ថែមផងដែរថា C-PIMA គឺជាម៉ូឌុលថ្មីដែលត្រូវបានគិតគូរដាក់បញ្ចូលក្នុង PIMA ដោយផ្តោតលើតែទិដ្ឋភាពនៃការរៀបចំក្របខ័ណ្ឌស្ថាប័នប៉ុណ្ណោះ (Institutional Strength)។ Clmate-PIMA ឬ C-PIMA ត្រូវបានរៀបចំសសរស្តម្ភចំនួន ៥ នៃការគ្រប់គ្រងការវិនិយោគសាធារណៈ ដែលជាគន្លឹះសម្រាប់ហេដ្ឋារចនាសម្ព័ន្ធឆ្លាតវៃនៃបម្រែបម្រួលអាកាសធាតុ(Climate-Smart Infrastructure) ដូចជា៖

*១. ការរៀបចំផែនការ (Planning)៖* ការតម្រឹមផែនការជាតិនិងតាមវិស័យ និងដោយភ្ជាប់គម្រោងវិនិយោគ (Investment Portfolios) ទៅនឹងគោលបំណងបម្រែបម្រួលអាកាសធាតុ គឺមានសារសំខាន់សម្រាប់ហេដ្ឋារចនាសម្ព័ន្ធវិស័យសាធារណៈ ដែលអាចធន់នឹងបម្រែបម្រួលអាកាសធាតុនិងប្រកបដោយចីរភាព។ ដំណាក់កាលនេះក៏ជាការបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងការរៀបចំផែនការ និងតម្រូវការនៃការសាងសង់ដែលមានផងដែរ។

*២. ការសម្របសម្រួល (Coordination)៖* ការវិនិយោគសាធារណៈអាចពាក់ព័ន្ធនឹងអង្គភាពរដ្ឋាភិបាល សហគ្រាសសាធារណៈ និងភាពជាដៃគូរវាងរដ្ឋនិងឯកជន។ ការធ្វើសមាហរណកម្ម ការពិចារណាពាក់ព័ន្ធនឹងបៃតងទៅក្នុងការវិនិយោគសាធារណៈ មានន័យថាជាការសម្របសម្រួលរាល់ភាគីពាក់ព័ន្ធទាំងអស់ នៃវិស័យសាធារណៈ និងក្រុមហ៊ុនចម្រុះ (Joint-Venture) ជាមួយវិស័យឯកជន។

*៣. ការវាយតម្លៃសំណើគម្រោង និងការជ្រើសរើសគម្រោង (Project Appraisal and Selection)៖* ជាដំណាក់កាលសំខាន់នៅក្នុងដំណើរការធ្វើការសម្រេចចិត្តលើគម្រោងហេដ្ឋារចនាសម្ព័ន្ធចម្បងៗ និងជាដំណាក់កាល ដែលកំណត់ថាគម្រោងណាមួយត្រូវធ្វើ។ ទន្ទឹមនេះ, ដំណាក់កាលនេះត្រូវបានដាក់បញ្ចូលការវិភាគ ការកាត់បន្ថយ និងបន្សាំពាក់ព័ន្ធនឹងបម្រែបម្រួលអាកាសធាតុ ដែលជះឥទ្ធិពលដល់ការវិនិយោគនានា ផងដែរ។

*៤. ការរៀបចំថវិកា និងការគ្រប់គ្រងគម្រោង (Budgeting and Portfolio Management)៖* ការវិនិយោគបែតង និងការវិភាជការថែទាំគួរតែត្រូវបានរៀបចំថវិកា និងរាយការណ៍តាមរយៈថវិកាប្រចាំឆ្នាំ និងឧបករណ៍ហិរញ្ញវត្ថុដទៃទៀតដូចជា ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋាភិបាល។ ការគ្រប់គ្រងទ្រព្យសម្បត្តិ និងការធ្វើសវនកម្មមុនក្រោយ (Ex-Post Audit) និងការពិនិត្យឡើងវិញគួរគិតគូរដូចគ្នាទៅនឹងគោលបំណងនៃការប្រែប្រួលអាកាសធាតុ។

*៥. ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ (Fiscal Risk Management)៖* បម្រែបម្រួលអាកាសធាតុពាក់ព័ន្ធនឹងហានិភ័យនឹងជះឥទ្ធិពលខ្លាំងទៅលើការវិនិយោគសាធារណៈ និងការរៀបចំថវិកា។ យុទ្ធសាស្ត្រគ្រប់គ្រងគ្រោះមហន្តរាយធម្មជាតិនិងការវិភាគហានិភ័យហិរញ្ញវត្ថុត្រូវបញ្ចូលទៅក្នុងហានិភ័យនេះនិងការគិតគូរកាត់បន្ថយហានិភ័យពីការប្រែប្រួលអាកាសធាតុផងដែរ។

ជាមួយគ្នានេះ, C-PIMA ក៏ធ្វើការវាយតម្លៃភាពប្រទាក់ក្រឡាគ្នា (Cross-Cutting Issues) ចំនួន ៣ ស្រដៀងគ្នាទៅនឹងការវាយតម្លៃក្នុង PIMA ផងដែរ ដូចជា៖

*១. ក្របខ័ណ្ឌគតិយុត្ត (Legal Framework)៖* ក្របខ័ណ្ឌគតិយុត្តមានសារសំខាន់ដើម្បីពិចារណានូវខ្លឹមសារគតិយុត្តទាំងមូល។ ខ្លឹមសារពាក់ព័ន្ធអាចរួមបញ្ចូលនូវភាពខ្វះចន្លោះនៃគតិយុត្ត គោលដៅបម្រែបម្រួលអាកាសធាតុ ការត្រួតពិនិត្យ និងការរាយការណ៍ពីតម្រូវការនានា ឧបករណ៍គតិយុត្តសម្រាប់អ្នករៀបចំគោលនយោបាយលើកកម្ពស់មុខងារ និងចីរភាពនៃប្រព័ន្ធអភិបាលកិច្ចបម្រែបម្រួលអាកាសធាតុ ច្បាប់ និងបទប្បញ្ញត្តិ PIM ដែលគ្របដណ្តប់មុខងារវិនិយោគសាធារណៈ។

*២. ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Information Systems)៖* ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានជួយគាំទ្រ PIM តាមរយៈការប្រមូលទិន្នន័យពាក់ព័ន្ធបម្រែបម្រួលអាកាសធាតុរួមមាន៖ ប្រព័ន្ធ IT ឬបណ្តុំទិន្នន័យដទៃទៀតពាក់ព័ន្ធគម្រោងនិងព័ត៌មានអំពីទ្រព្យសម្បត្តិដែលអាចបញ្ចូលទៅក្នុងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរដ្ឋាភិបាល។

*៣. សមត្ថភាពបុគ្គលិក (Staff Capacity)៖* បណ្តុះបណ្តាលសមត្ថភាព និងជំនាញបុគ្គលិក ដើម្បីឆ្លើយតប និងគាំទ្រនៅក្នុងគោលនយោបាយបម្រែបម្រួលអាកាសធាតុ ដូចជាការកាត់បន្ថយ និងបន្សាំការប្រែប្រួលអាកាសធាតុទៅក្នុង PIM និងទៅលើទិដ្ឋភាពបច្ចេកទេសពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ។ ហេតុដូច្នេះ ការរៀបចំ គាំទ្រ និងបង្កើតការលើកទឹកចិត្តសម្រាប់គ្រប់គ្រងការផ្លាស់ប្តូរដើម្បីបញ្ចូលទៅក្នុងការប្រែប្រួលអាកាសធាតុក្នុងការរៀបចំគម្រោង ការសម្រេចចិត្ត និងការផ្តល់នូវការបណ្តុះបណ្តាល ជាការងារអាទិភាព និងចាំបាច់។

ជារួម ការវាយតម្លៃការគ្រប់គ្រងការវិនិយោគសាធារណៈ ដោយរួមបញ្ចូលការវាយតម្លៃពាក់ព័ន្ធបម្រែបម្រួលអាកាសធាតុនឹងផ្តល់នូវអនុសាសន៍កែលម្អក្នុងការបំពេញចំណុចខ្វះខាតទាំងក្នុងក្របខ័ណ្ឌគតិយុត្ត និងក្របខ័ណ្ឌស្ថាប័ននៃការអនុវត្តកន្លងមក ដើម្បីពង្រឹងប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងផ្តល់នូវសេវាសាធារណៈកាន់តែប្រសើរជូនប្រជាពលរដ្ឋគ្រប់រូប៕




**រូបភាព៖ ការវាយតម្លៃ PIMA និង C-PIMA**


*ឯកសារយោង៖*

*PIMA Handbook: Public Investment Management Assessment (1st ed.). (2022, July 8). International Monetary Fund.*
https://www.imf.org/en/Publications/Books/Issues/2022/07/12/PIMA-Handbook-Public-Investment-Management-Assessment-1st-Edition-50166

*Strengthening Infrastructure Governance for Climate-Responsive Public Investment. (2021, December 3). International Monetary Fund.*
https://www.imf.org/en/Publications/Policy-Papers/Issues/2021/12/22/Strengthening-Infrastructure-Governance-for-Climate-Responsive-Public-Investment-511258


រៀបចំអត្ថបទដោយ៖ ផ្នែកអនុវត្តថវិកា នៃ អ.គ.ហ.

# បច្ចេកវិទ្យាហិរញ្ញវត្ថុ

## ដើម្បីសេដ្ឋកិច្ច និងសង្គមឌីជីថល

## កម្ពុជាដ៏រស់រវើក



## ១. ទិដ្ឋភាពទូទៅនៃបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា

ក្នុងបរិការណ៍សកលភាវូបនីយកម្មនិងតំបន់ភាវូបនីយកម្ម បច្ចេកវិទ្យាបាន និងកំពុងធ្វើបរិវត្តកម្មឌីជីថលក្នុងគ្រប់វិស័យ នៃសេដ្ឋកិច្ច និងសង្គម។ ក្នុងនោះ ការធ្វើបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុធ្វើឱ្យលេចឡើងនូវបច្ចេកវិទ្យាហិរញ្ញវត្ថុ (Financial Technology - FinTech) ដែលជាប្រភពថ្មីនៃកំណើនសេដ្ឋកិច្ចឌីជីថលនិងសុខុមាលភាពសង្គមវៃឆ្លាត។ដោយមើលឃើញពីសក្តានុពលភាព និងកាលានុវត្តភាពដ៏ធំធេង នៃបច្ចេកវិទ្យាហិរញ្ញវត្ថុ ក្នុងការរួមចំណែកជំរុញសម្ទុះ នៃការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា, រាជរដ្ឋាភិបាលបាន និងកំពុងយកចិត្តទុកដាក់ខ្ពស់ លើការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ។សម្រាប់កម្ពុជាបច្ចេកវិទ្យាហិរញ្ញវត្ថុសំដៅដល់បច្ចេកវិទ្យានិងនវានុវត្តន៍ក្នុងវិស័យហិរញ្ញវត្ថុទាំងវិស័យធនាគារនិងវិស័យហិរញ្ញវត្ថុមិនមែនធនាគារបង្កើតឡើងដើម្បីឱ្យមានការប្រើប្រាស់ ផ្តល់ និងទទួលសេវាហិរញ្ញវត្ថុបានទូលំទូលាយប្រកបដោយបរិយាបន្នកម្ម។



ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ, បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាមានការអភិវឌ្ឍគួរឱ្យកត់សម្គាល់ ជាពិសេសក្នុងអំឡុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ បន្ទាប់ពីរាជរដ្ឋាភិបាលបានឆ្លើយតបទាន់ពេល ក្នុងស្មារតីបុរេសកម្ម តាមរយៈការចាក់វ៉ាក់សាំងបង្កើតភាពស៊ាំសហគមន៍ក៏ដូចជាការដាក់ចេញនូវគោលនយោបាយយុទ្ធសាស្ត្រនិងផែនទីមគ្គុទេសក៍គន្លឹះៗពាក់ព័ន្ធផ្សេងទៀតដើម្បីអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផលដល់ទីផ្សារ។ ទោះបីជាយ៉ាងនេះក្តី បច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ស្ថិតនៅដំណាក់កាលលូតលាស់ដំបូងនៅឡើយ ការណ៍នេះទាមទារនូវការយកចិត្តទុកដាក់អភិវឌ្ឍបន្ថែមទៀតពីរាជរដ្ឋាភិបាលនិងការចូលរួមពីវិស័យឯកជន។

ប្រសិនបើប្រៀបធៀបនឹងប្រទេសក្នុងតំបន់ ស្ថានភាពបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាមិនស្ថិតនៅក្រោយគេនោះទេប៉ុន្តែស្ថិតនៅក្នុងចំណោមប្រទេសដែលមិនទាន់អាចទាញយកអត្ថប្រយោជន៍ជាអតិបរមានៅឡើយដោយហេតុថាប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាមិនទាន់មានលក្ខណៈរស់រវើក ពោលគឺមានកង្វះខាតការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផលការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រនិងការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ។ដោយសារមានការគាំទ្រពីរាជរដ្ឋាភិបាលបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជានឹងមានសក្តានុពលភាព និងកាលានុវត្តភាពខ្ពស់ទៅថ្ងៃអនាគត។







0101100010100101101001101


Fintech

## ២. ការរៀបចំនិងការអនុវត្តគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨

អាស្រ័យហេតុនេះហើយរាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវ "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា២០២៣-២០២៨" ក្នុងស្មារតីឆ្លើយតបទៅនឹងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជា២០២១-២០៣៥ក៏ដូចជាបទពិសោធន៍ឧត្តមានុវត្តន៍និងនិន្នាការអន្តរជាតិនៃការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុដែលមានសមានគតិភាពជាមួយនឹងស្ថានភាពកម្ពុជាក្នុងដំណើរសម្លឹងឆ្ពោះទៅមុខប្រកបដោយក្តីសង្ឃឹមភាពជឿជាក់និងឆន្ទៈមោះមុតក្នុងការសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០និងចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ក្រោមបាវចនា "ក្តាប់មកវិញនូវមោទនភាពជាតិ កសាងជាតិដ៏រស់រវើក"។ គោលនយោបាយនេះមានចក្ខុវិស័យរយៈពេលវែង "អភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយឈរលើមូលដ្ឋាននៃការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ និងការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ ដើម្បីចាប់យកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងផ្តល់កាលានុវត្តភាពដល់គ្រប់តួអង្គពាក់ព័ន្ធសំដៅរួមចំណែកជំរុញសន្ទុះនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថលកម្ពុជាដ៏រស់រវើក"។សម្រាប់ចក្ខុវិស័យរយៈពេលវែងនេះ,គោលនយោបាយនេះមានគោលបំណង "អភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុរស់រវើក តាមរយៈការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផល,ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះ,ការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ និងការជំរុញការអភិវឌ្ឍ និងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុដើម្បីធ្វើឱ្យប្រសើរឡើងនូវប្រចកទទួលសេវាហិរញ្ញវត្ថុ,ភាពជឿទុកចិត្តនិងគុណភាពជីវិតរបស់អ្នកប្រើប្រាស់ ក្នុងយុគសម័យឌីជីថល"។



ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងខាងលើ, គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាបានដាក់ចេញនូវគោលដៅចម្បងដែលជាផ្នែកទាំង ៤ នៃដើមឈើបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា គឺ(១)-ការអភិវឌ្ឍបរិស្ថានគោលនយោបាយអំណោយផលដែលតំណាងដោយ "ដី",(២)-ការអភិវឌ្ឍថ្នាលឌីជីថលគ្រឹះដែលតំណាងដោយ"ឫស",(៣)-ការជំរុញការប្រើប្រាស់និងការអភិវឌ្ឍបច្ចេកវិទ្យាគាំទ្រ ដែលតំណាងដោយ "ដើម" និង(៤)-ការជំរុញការអភិវឌ្ឍនិងនវានុវត្តន៍សកម្មភាពបច្ចេកវិទ្យាហិរញ្ញវត្ថុដែលតំណាងដោយ"មែក"។ដើម្បីសម្រេចចក្ខុវិស័យនិងគោលបំណងខាងលើ,គោលនយោបាយនេះបានដាក់ចេញនូវវិធានការគោលនយោបាយសរុបចំនួន ៥២ ដោយធ្វើសុខដុមនីយកម្ម និងសមាហរណកម្មវិធានការគោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុមិនមែនធនាគារ ដែលទទួលបន្ទុកអនុវត្តដោយធនាគារជាតិនៃកម្ពុជា មជ្ឈមណ្ឌលបច្ចេកវិទ្យាហិរញ្ញវត្ថុនិងនិយ័តករក្រោមឱវាទអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ និងក្រសួង ស្ថាប័នពាក់ព័ន្ធនៃរាជរដ្ឋាភិបាល។

សម្រាប់ការអនុវត្តគោលនយោបាយនេះ, រាជរដ្ឋាភិបាលបានកំណត់យកគោលការណ៍ចម្បងៗ ចំនួន ៣ គឺ (១)-ការលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, (២)-ការរក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុនិង(៣)-ការជំរុញនវានុវត្តន៍ហិរញ្ញវត្ថុ។ដើម្បីអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជាផ្អែកលើគោលការណ៍ខាងលើ, ការអនុវត្តគោលនយោបាយ ប្រើប្រាស់អភិក្រមចម្បងចំនួន ៣ គឺ (១)-ការចាប់យក, (២)-ការកែសម្រួល និង(៣)-ការធ្វើនវានុវត្តន៍បន្ថែម ស្របតាមគោលគំនិត "ទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបរិវត្តកម្មឌីជីថលក្នុងវិស័យហិរញ្ញវត្ថុ និងកាត់បន្ថយហានិភ័យឱ្យស្ថិតក្នុងកម្រិតអប្បបរមា"ដោយឈរលើគោលជំហរ"ថែទាំដើមឈើឱ្យលូតលាស់ល្អនិងអាស្រ័យផលបានត្រូវការដីមានជីជាតិដែលអំណោយផលដល់ការស្រូបយករបស់ឫស, ឫសមាំ និងច្រើនដែលអាចស្រូបយកជីជាតិបានល្អសម្រាប់ទ្រទ្រង់ដល់ភាពរឹងមាំរបស់ដើម, ដើមរឹងមាំសម្រាប់ទ្រទ្រង់ដល់ការលូតលាស់ល្អរបស់មែកនិងបែកមែកសាខាប្រកបដោយផ្លែផ្កាច្រើន ដែលអាចអាស្រ័យផលបាន"។

ទន្ទឹមនេះ, សម្រាប់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា, ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ បានក្លាយជាមុំទី ៥ នៃបញ្ចកោណទី ៥ "ការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមឌីជីថល" នៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ ដែលមានអាទិភាពការងារចំនួន ៧ ពាក់ព័ន្ធនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត, ហិរញ្ញវត្ថុបើកចំហ, ថ្នាលឌីជីថលគ្រឹះ, ប្រព័ន្ធទូទាត់សងប្រាក់ឌីជីថល, បច្ចេកវិទ្យាគាំទ្រ, បច្ចេកវិទ្យានិយ័តកម្មនិងបច្ចេកវិទ្យាត្រួតពិនិត្យ និងប្រព័ន្ធអេកូឡូស៊ីបច្ចេកវិទ្យាហិរញ្ញវត្ថុ តាមរយៈការអនុវត្តគោលនយោបាយខាងលើ សម្រាប់គាំទ្រដល់របៀបវារៈគោលនយោបាយនិងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល សម្រាប់រយៈពេល ៥ ឆ្នាំ ទៅមុខ៕

## មុំទី ៥ នៃបញ្ចកោណទី ៥៖ ការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ

គោលដៅជាយុទ្ធសាស្ត្រ គឺការអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុ ដោយចាប់យកកាលានុវត្តភាព និងទាញយកអត្ថប្រយោជន៍ជាអតិបរមាពីបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់បរិយាបន្នហិរញ្ញវត្ថុ, រក្សាស្ថិរភាពវិស័យហិរញ្ញវត្ថុ, និងជំរុញការនវានុវត្តន៍ហិរញ្ញវត្ថុ តាមរយៈការអនុវត្ត "គោលនយោបាយអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុកម្ពុជា ២០២៣-២០២៨"




**គំនូសបំព្រួញស្ដីពី "យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១"**

ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព៖ កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៥០

រៀបចំអត្ថបទដោយ៖ អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

# បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា

ខែវិច្ឆិកា ឆ្នាំ២០២៣



## ពីការស្ទុះងើប សេដ្ឋកិច្ចឡើងវិញ ឆ្ពោះទៅរកកំណែទម្រង់

សកម្មភាពសេដ្ឋកិច្ចនៅឆ្នាំនេះ មានការស្ទុះងើបឃើតយ៉ាវជាងការរំពឹងទុកកន្លងមកដោយសារបញ្ហាផ្នែករចនាសម្ព័ន្ធដែលកំពុងលេចឡើងនិងឧបសគ្គខាងក្រៅដែលកំពុងបន្តកើតមាន។ ប្រការនេះបានជំរុញឱ្យមានការប្រញាប់ប្រញាល់ដោះស្រាយបញ្ហាប្រឈមសេដ្ឋកិច្ចដែលកំពុងកើនឡើង ដើម្បីរក្សាកំណើនសេដ្ឋកិច្ចឱ្យមាននិរន្តរភាពក្នុងរយៈពេលខ្លីដល់មធ្យម។ ខណៈពេលដែលការថមថយសេដ្ឋកិច្ចជាលក្ខណៈរចនាសម្ព័ន្ធរបស់ប្រទេសកម្ពុជាបានចាប់ផ្តើមកើតមានមុនពេលមានជំងឺរាតត្បាត ការថមថយនេះត្រូវបានបិទបាំងអស់រយៈពេលជាច្រើនឆ្នាំ ដោយលំហូរចូលមូលធនយ៉ាងឆាប់រហ័ស ដែលភាគច្រើនមកពីប្រទេសចិន ដែលជំរុញឱ្យមានការរីកចម្រើនផ្នែកសំណង់រហូតដល់ពេលមានការផ្ទុះឡើងនូវជំងឺកូវីដ-១៩។ ក្នុងរយៈពេលបីខែដំបូងក្នុងឆ្នាំ២០២៣ ការនាំចេញទំនិញបានធ្លាក់ចុះ ២ ភាគរយ។ ការនាំចូលទំនិញក៏បានធ្លាក់ចុះផងដែរខណៈពេលដែលការនាំចូលមាសបានធ្លាក់ចុះដែលធ្វើឱ្យឱនភាពគណនីចរន្តរួមតូច បើទោះបីជាការនាំចេញទន់ខ្សោយក៏ដោយ។ ប្រការនេះបានជួយបន្ធូរបន្ថយសម្ពាធលើអត្រាប្តូរប្រាក់ដែលនៅតែមានស្ថិរភាពយ៉ាងទូលំទូលាយដោយរក្សាបានក្នុងតម្លៃ ៤.១០០ រៀល ក្នុងមួយដុល្លារអាម៉េរិក។ នៅពេលដែលតម្លៃអាហារនិងប្រេងឥន្ធនៈស្ទុះងើប ៣,២ ភាគរយ ក្នុងខែសីហា ឆ្នាំ២០២៣ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ធៀបនឹង ២,៨ ភាគរយ នៅដំណាច់ឆ្នាំ២០២២។ ទុនបម្រុងរូបិយប័ណ្ណអន្តរជាតិដុលបានកើនឡើងដល់ ១៨,៥ ពាន់លានដុល្លារអាម៉េរិក នៅដំណាច់ឆ្នាំ២០២២ ដែលគ្របដណ្តប់ការចំណាយលើការនាំចូលទំនិញបានប្រហែលប្រាំពីរខែ។ កំណើនឥណទានបានធ្លាក់ចុះមកត្រឹម ៧,៧ ភាគរយ ក្នុងខែសីហា ឆ្នាំ២០២៣ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលជាកម្រិតទាបបំផុតក្នុងរយៈពេល ២០ ឆ្នាំ ដោយធ្លាក់ចុះពីកំណើន ២២,៧ ភាគរយ ក្នុងកំឡុងពេលដូចគ្នា ក្នុងឆ្នាំ២០២២ ដែលរារាំងបន្ថែមទៀតដល់ការប្រើប្រាស់ក្នុងស្រុក។






បន្ទាប់ពីការស្ទុះងើបឡើងវិញខ្លាំង នៅឆ្នាំ២០២២ ការប្រមូលចំណូលរបស់រដ្ឋាភិបាលបានធ្លាក់ចុះនៅឆ្នាំនេះ។ ដោយសារតែកំណើនប្រាក់ចំណូលពីភាពប្រសើរឡើងនៃការគ្រប់គ្រងប្រាក់ចំណូលអាចឈានដល់កម្រិតកំពូលរួចហើយ នោះហើយវដ្តធ្លាក់ចុះក្នុងគ្រាដែលការថមថយសកម្មភាពសេដ្ឋកិច្ចបានបន្តកើតមានការប្រមូលប្រាក់ចំណូលដោយផ្ទាល់បានថយចុះ។ ដូចនេះដែរ ពន្ធលើទំនិញនិងសេវាកម្ម ជាពិសេសពន្ធគយលើការនាំចូលបានធ្លាក់ចុះ ដោយសារការនាំចូលទំនិញនិងការប្រើប្រាស់បានថយចុះ។ពន្ធលើពាណិជ្ជកម្មអន្តរជាតិក៏បានថមថយផងដែរក្នុងគ្រាដែលមានការធ្លាក់ចុះពាណិជ្ជកម្ម។ក្នុងរយៈពេលប្រាំបីខែដំបូងក្នុងឆ្នាំ២០២៣ប្រាក់ចំណូលក្នុងស្រុករបស់រដ្ឋាភិបាលកណ្តាលបានកើនឡើងតិចតួចដោយកើនឡើង០,៤ភាគរយប៉ុណ្ណោះធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនធ្លាក់ចុះពី២៣,៨ ភាគរយ ក្នុងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២២។ ទោះជាយ៉ាងណា កំណើនចំណាយរបស់រដ្ឋាភិបាលកណ្តាលបានកើនឡើងដល់១២,៧ភាគរយធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុនជាចម្បងដោយសារការកើនឡើងការចំណាយប្រតិបត្តិការ ដែលរួមមានដូចជាការដំឡើងប្រាក់ឈ្នួលក្នុងវិស័យសាធារណៈ ការកើនឡើងការចំណាយលើទំនិញ និងសេវាកម្ម ការចំណាយទាក់ទងនឹងការបោះឆ្នោតសកល និងការធ្វើជាម្ចាស់ផ្ទះកីឡាអាស៊ីអាគ្នេយ៍ និងកីឡាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍(អាស៊ាន)ប៉ារ៉ាហ្គេមក៏ដូចជាការកើនឡើងការចំណាយមូលធន។ប្រាក់បញ្ញើរបស់រដ្ឋាភិបាល (ទុនបម្រុងសារពើពន្ធ) បានធ្លាក់ចុះតិចតួចមកនៅត្រឹម ២១,៣៣ ពាន់ពាន់លានរៀល (៥,១ ពាន់លានលានដុល្លារអាម៉េរិក) ឬស្មើនឹង ១៦ ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងខែសីហា ឆ្នាំ២០២៣ ធ្លាក់ចុះពី ២១,៩ ពាន់លានរៀល (៥,៣ ពាន់លានដុល្លារ) ឬស្មើនឹង ១៧,៨ ភាគរយ នៃផលិតផលក្នុងស្រុកសរុបក្នុងឆ្នាំ២០២២។ ទីផ្សារការងារទទួលរងផលប៉ះពាល់ពីការធ្លាក់ចុះការនាំចេញទំនិញ។ ជាលទ្ធផល ការងារនៅក្នុងវិស័យកម្មន្តសាល (ក្នុងប្រព័ន្ធ) ដែលជាប្រភពសំខាន់នៃការងារដែលមានប្រាក់ឈ្នួលដែលមានចំនួន ១៨ ភាគរយ នៃប្រាក់បៀវត្សមិនមែនកសិកម្ម បានធ្លាក់ចុះពី ១,០៥ លានកន្លែង ក្នុងខែសីហា ឆ្នាំ២០២៣។ កត្តានេះតំណាងឱ្យការធ្លាក់ចុះ ៥ ភាគរយ នៃការងារក្នុងវិស័យកម្មន្តសាល ដែលជំរុញឱ្យអាជ្ញាធរផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់កម្មករ ដែលត្រូវបានបញ្ឈប់ពីការងារ។ ជំនួយផ្នែកហិរញ្ញវត្ថុស្រដៀងគ្នានេះដែរដែលធ្វើឡើងក្នុងទម្រង់ជា"ការឧបត្ថម្ភធនប្រាក់ឈ្នួល"ដែលជាវិធានការជំនួយមួយក្នុងចំណោមវិធានការជំនួយជាច្រើនត្រូវបានផ្តល់ជូនក្នុងអំឡុងពេលកើតមានជំងឺរាតត្បាតកូវីដ-១៩។ក្នុងចំណោមកម្មវិធីជំនួយសង្គមទាំងអស់ កម្មវិធីឧបត្ថម្ភសាច់ប្រាក់កូវីដ-១៩ គឺជាកម្មវិធីធំជាងគេ។ ចាប់តាំងពីការដាក់ដំណើរការនៅក្នុងខែមិថុនា ឆ្នាំ២០២០ មក កម្មវិធីនេះបានបញ្ចេញថវិកាចំនួន ១,២ ពាន់លានដុល្លារអាម៉េរិក គិតត្រឹមខែកញ្ញា ឆ្នាំ២០២៣។ លើសពីនេះទៀត រដ្ឋាភិបាលបានបង្កើតកម្មវិធីឧបត្ថម្ភសាច់ប្រាក់ ដោយភ្ជាប់ល័ក្ខខ័ណ្ឌរបស់ខ្លួនទ្វេដងដល់ប្រមាណជា ៣៨០ ដុល្លារអាម៉េរិក សម្រាប់ស្ត្រីមានផ្ទៃពោះម្នាក់ៗ ដែលមានកូនម្នាក់រហូតដល់អាយុ ២ ឆ្នាំ ដែលមានប័ណ្ណក្រីក្រIDPoorចាប់ពីខែសីហាឆ្នាំ២០២៣។កម្មវិធីជំនួយនេះក៏បានពង្រីកវិសាលភាពគ្របដណ្តប់របស់ខ្លួនផងដែរ ដើម្បីរួមបញ្ចូលកម្មការិនីដែលជាសមាជិកបេឡាជាតិរបបសន្តិសុខសង្គម (បសស) មន្ត្រីរាជការស្ត្រី អ្នកហាត់ការងារ និងមន្ត្រីរដ្ឋាភិបាលជាប់កិច្ចសន្យា។ ការកើនឡើងជំនួយជាសាច់ប្រាក់ និងការពង្រីកវិសាលភាពគ្របដណ្តប់របស់កម្មវិធីទាំងនេះ ជួយកាត់បន្ថយទៀតនូវផលប៉ះពាល់អវិជ្ជមាន ដែលគ្រួសារក្រីក្រ និងងាយរងគ្រោះបានជួបប្រទះ។ កំណើនផលិតផលក្នុងស្រុកសរុប (ផសស) ពិតរបស់កម្ពុជាត្រូវបានព្យាករណ៍ថានឹងកើនឡើងដល់ ៥,៤ ភាគរយ នៅឆ្នាំ២០២៣ដែលទាបជាងបន្តិចពីអត្រា៥,៥ភាគរយដែលបានព្យាករណ៍ក្នុងខែឧសភាឆ្នាំ២០២៣(សូមមើលតារាង ES១) ដោយសារតម្រូវការក្នុងស្រុកបានថយចុះ ហើយតម្រូវការខាងក្រៅបានបន្តធ្លាក់ចុះ។ ឱនភាពសារពើពន្ធនៅឆ្នាំនេះ ត្រូវបានរំពឹងថានឹងកើនឡើងដល់ ៦,៩ ភាគរយ នៃផលិតផលក្នុងស្រុកសរុបកើនឡើងពី ៤,៨ ភាគរយ នៃផលិតផលក្នុងស្រុកសរុប ក្នុងឆ្នាំ២០២២។

## តារាង ES១៖ ចក្ខុវិស័យម៉ាក្រូ

*(ភាគរយនៃ ផ.ស.ស. លុះត្រាតែមានការបង្ហាញផ្សេងពីនេះ)*

| | ការព្យាករ | | | ប្រែប្រួលធៀបនឹង ខែឧសភា ឆ្នាំ២០២៣ | | |
|---|---|---|---|---|---|---|
| | ២០២៣ | ២០២៤ | ២០២៥ | ២០២៣ | ២០២៤ | ២០២៥ |
| **កំណើនពិត** (ភាគរយ) | ៥,៤ | ៥,៨ | ៦,១ | -០,១ | -០,៣ | -០,២ |
| **CPI** (រយៈពេលជាមធ្យម, ភាគរយ) | ៣ | ២,៨ | ២,៧ | ០,៥ | ០,៣ | ០,៧ |
| **គណនីចរន្ត** | -១៣,៤ | -១១,៥ | -៩,៦ | ៥,៩ | ៤,៦ | ៣,៦ |
| **ឱនភាពសារពើពន្ធរួម** | -៦,៩ | -៤,៨ | -៣,២ | -០,៥ | ០,១ | ១ |
| **បំណុលខាងក្រៅសាធារណៈ** | ៣៦,៩ | ៣៦,៣ | ៣៥,៦ | ១,៨ | ០,៧ | -០,៣ |

បច្ចុប្បន្នភាពសេដ្ឋកិច្ចកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០២៣

ក្នុងរយៈពេលខ្លីការប៉ះទង្គិចអវិជ្ជមានដែលបង្កឡើងដោយជំងឺរាតត្បាតការឈ្លានពានរបស់រុស្ស៊ីលើប្រទេសអ៊ុយក្រែន និងការរឹតបន្តឹងយ៉ាងខ្លាំងនៃគោលនយោបាយរូបិយវត្ថុក្នុងប្រទេសដែលមានសេដ្ឋកិច្ចធំៗដើម្បីទប់ស្កាត់កំណើនអតិផរណាត្រូវបានគេរំពឹងថានឹងបន្តប៉ះពាល់ដល់សេដ្ឋកិច្ច។ នៅក្នុងបរិបទនេះសេដ្ឋកិច្ចត្រូវបានព្យាករណ៍ថា នឹងបន្តកើនឡើងក្នុងល្បឿនយឺតជាងការព្យាករនាពេលកន្លងមកដោយកើនឡើងក្នុងអត្រា ៦,៨ ភាគរយ នៅក្នុងឆ្នាំ២០២៤ និង ៦,១ ភាគរយ នៅក្នុងឆ្នាំ២០២៥។ ក្នុងរយៈពេលមធ្យមទៅវែង កំណើនផលិតផលក្នុងស្រុកសរុបពិតត្រូវបានរំពឹងថានឹងវិលត្រលប់ទៅរកសក្តានុពលវិញ ដោយកើនឡើងដល់ចន្លោះពី ៦ ទៅ ៧ ភាគរយ ដែលជំរុញដោយការនាំចេញខ្លាំងជាងមុន និងលំហូរចូលនៃការវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលសម្របសម្រួល ដោយកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលត្រូវបានផ្តល់សច្ចាប័នថ្មីៗការកើនឡើងយ៉ាងច្រើននៃការវិនិយោគឯកជន និងសាធារណៈនៅក្នុងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសំខាន់ៗ និងកំណែទម្រង់រចនាសម្ព័ន្ធ។ ជាងនេះទៀត គម្លាតក្នុងការតភ្ជាប់ទៅកាន់តំបន់ប៉ះពាល់ដល់ប្រសិទ្ធភាព និងការចំណាយលើការធ្វើពាណិជ្ជកម្មឆ្លងព្រំដែន ហើយចាំបាច់ត្រូវដោះស្រាយ។ ការវិនិយោគត្រូវការជាចាំបាច់ដើម្បីដោះស្រាយគម្លាតហេដ្ឋារចនាសម្ព័ន្ធជាក់លាក់ក្នុងការតភ្ជាប់ការដឹកជញ្ជូនក្នុងស្រុក និងក្នុងតំបន់៖ ដើម្បីកែលម្អច្រករបៀងខាងកើត ខាងលិចឆ្លងកាត់ប្រទេសថៃ កម្ពុជា និងវៀតណាម (និងច្រករបៀងផ្លូវគោកតែមួយគត់ ដែលតភ្ជាប់ប្រទេសកម្ពុជាជាមួយប្រទេសឡាវ) កែលម្អការតភ្ជាប់ផ្លូវទឹកជាមួយវៀតណាម និងធ្វើឱ្យប្រសើរឡើងនូវប្រតិបត្តិការផ្លូវដែកដែលមានស្រាប់ និងការតភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធជាមួយប្រទេសថៃ។ ការធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលពាណិជ្ជកម្ម និងដំណើរការដឹកជញ្ជូនក៏មានសារៈសំខាន់ផងដែរ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតត្រូវតែធ្វើឡើងដើម្បីកាត់បន្ថយថ្លៃដឹកជញ្ជូន និងឡជីស្ទិកតាមរយៈការត្រួតពិនិត្យប្រសិទ្ធភាពច្រកទ្វារពាណិជ្ជកម្មសំខាន់ៗ ដូចជាកំពង់ផែ និងច្រកព្រំដែនជាដើម៕

រៀបចំអត្ថបទដោយៈ ធនាគារពិភពលោក (World Bank)

# ផ្នែកទី ៣

# សុន្ទរកថា


នាយករដ្ឋមន្ត្រី


នាយករដ្ឋមន្ត្រី

# សុន្ទរកថា
# របស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
# ថ្លែងក្នុងពិធីបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៣
# ក្រោមប្រធានបទ
# «ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ទៀត៖ ការកំណត់មាគ៌ា សម្រាប់វិបុលភាព ប្រកបដោយភាពធន់ និរន្តរភាព និង បរិយាប័ន្ន»

ថ្ងៃព្រហស្បតិ៍ ១១ កើត ខែកត្តិក ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២៣

- **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ, ខ្ញុំពិតជាមានក្តីសោមនស្ស ដោយបានចូលរួមជាអធិបតី ក្នុងពិធីបើក សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០២៣ ក្រោមប្រធានបទ «ចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០៣០ និង ឆ្នាំបន្តបន្ទាប់ទៀត៖ ការកំណត់មាគ៌ា សម្រាប់វិបុលភាព ប្រកបដោយភាពធន់ និរន្តរភាព និង បរិយាប័ន្ន»។ ខ្ញុំសូមថ្លែងអំណរគុណ និង វាយតម្លៃខ្ពស់ចំពោះវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ដែលបានសហការជាមួយស្ថាប័នជាតិ និង អន្តរជាតិនានាជាច្រើន រៀបចំសន្និសីទដ៏មានសារៈសំខាន់នេះឡើង។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះថ្នាក់ដឹកនាំនៃក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាល វិស័យឯកជន វិទ្យាស្ថានស្រាវជ្រាវ អង្គការជាតិ និង អន្តរជាតិ និង ដៃគូអភិវឌ្ឍន៍នានា ដែលបានអញ្ជើញចូលរួមដោយផ្ទាល់ក្នុងសន្និសីទនាពេលនេះ។

ខ្ញុំកត់សម្គាល់ឃើញថា ក្រោមកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ វិទ្យាស្ថាន CDRI បានរៀបចំសន្និសីទប្រចាំឆ្នាំនេះចំនួន ១៤ លើក រួចមកហើយ ពោលគឺចាប់តាំងពី ឆ្នាំ២០០៧ មកដល់ ឆ្នាំ២០២២ ដោយតែងតែទទួលបានការអញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ពីសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និង ជាអតីតនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។ សន្និសីទថ្ងៃនេះ គឺជាសន្និសីទប្រចាំឆ្នាំលើកទី ១៥ ហើយក៏ជាការចូលរួមលើកទី ១ របស់ខ្ញុំ ក្នុងតួនាទីជានាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

ដូចគ្នានឹងរាជរដ្ឋាភិបាលអាណត្តិមុនៗដែរ រាជរដ្ឋាភិបាលនីតិកាលទី ៧ នៃរដ្ឋសភា ចាត់ទុកសន្និសីទនេះជាវេទិកាដ៏សំខាន់ ដែលផ្តល់ឱកាសឱ្យតួអង្គពាក់ព័ន្ធទាំងអស់ ជាពិសេស «ស្ថាប័នស្រាវជ្រាវ» បានពិភាក្សា និងផ្លាស់ប្តូរយោបល់អំពីសមិទ្ធផល បញ្ហាប្រឈម និងទិសដៅយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ ដោយផ្តោតសំខាន់លើការអនុវត្តជាក់ស្តែងផង និងភាពបត់បែនទៅតាមការផ្លាស់ប្តូរនៃបរិការណ៍សកល និងតំបន់ផង ដើម្បីអាចនាំនាវាកម្ពុជាទៅកាន់វិបុលភាព ប្រកបដោយភាពធន់ និរន្តរភាព និងបរិយាប័ន្ន។ ដោយសារប្រធានបទឆ្នាំនេះ ផ្តោតលើការគិតគូរអំពីដំណើរកម្ពុជាក្នុងការឆ្ពោះទៅ ឆ្នាំ២០៣០ និងឆ្នាំបន្តបន្ទាប់ វត្តមានរបស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក និងលោកស្រី ព្រមទាំងការចូលរួមពិភាក្សាចែករំលែកនូវមតិយោបល់ក្នុងថ្ងៃនេះ បង្ហាញពីការប្តេជ្ញាចិត្តខ្ពស់ ក្នុងស្មារតីរួមចំណែក និងសហការគ្នា គូសវាស តម្រង់ទិស និង កំណត់ជោគវាសនាកម្ពុជា។

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី**!

ប្រាកដណាស់ថា ការគិតគូរទៅអនាគត ចាំបាច់ត្រូវឈរលើសមិទ្ធផលដែលសម្រេចបានកន្លងមក ពោលគឺការគិតពីអនាគតកាន់តែឆ្ងាយទៅមុខចាំបាច់ត្រូវពិនិត្យមើលអតីតកាលដើម្បីឱ្យមានមូលដ្ឋានគ្រប់គ្រាន់។ក្នុងន័យនេះខ្ញុំសូមអនុញ្ញាតរំលឹកឡើងវិញថាក្នុងរយៈពេលជាងពីរទសវត្សរ៍ចុងក្រោយនេះ ផ្តើមចេញពីនយោបាយឈ្នះ ឈ្នះរបស់ សម្តេចតេជោ **ហ៊ុន សែន** កម្ពុជាកសាងបាននូវមូលដ្ឋានគ្រឹះសេដ្ឋកិច្ចរឹងមាំសម្រាប់កិច្ចអភិវឌ្ឍដោយប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចទីផ្សារតាមរយៈ១).ការបើកចំហការធ្វើពាណិជ្ជកម្មអន្តរជាតិឈរលើគោលការណ៍ពហុភាគីនិយម២).ការជំរុញនិងទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសដើម្បីជាមូលដ្ឋានកសាងចន្ទល់ថ្មីៗសម្រាប់ទ្រទ្រង់កំណើនសេដ្ឋកិច្ច៣).ការពង្រឹង និងការស្តារហេដ្ឋារចនាសម្ព័ន្ធរឹង ដូចជា ផ្លូវ ថ្នល់ ទឹក និងភ្លើង ដើម្បីលើកកម្ពស់ការតភ្ជាប់ សម្រួលការចល័តធនធាន និងកម្លាំងពលកម្មក៏ដូចជាពង្រាយមូលដ្ឋានផលិតកម្ម៤).ការបន្តអភិវឌ្ឍនិងការលើកកម្ពស់មូលធនមនុស្សដើម្បីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច និងបង្កើនផលិតភាពនិង៥).ការកែទម្រង់ស្ថាប័ននិងអភិបាលកិច្ចជាប្រចាំដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងប្រព័ន្ធនយោបាយនិងសេដ្ឋកិច្ចរួមទាំង ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និង ប្រព័ន្ធធនាគារ ឱ្យមានប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ព្រមទាំងបែងចែកផ្លែផ្កាកំណើនឱ្យមានសមធម៌និងបរិយាប័ន្ន។

ជាលទ្ធផល កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចរឹងមាំ ប្រកបដោយចីរភាពក្នុងអត្រាជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ សម្រាប់រយៈពេលជាង ២ ទសវត្សរ៍កន្លងមក ដែលនាំឱ្យកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបក្នុង ឆ្នាំ២០១៥ ដោយទំហំផលិតផលក្នុងស្រុកសរុប (ផ.ស.ស.) កើនឡើងប្រមាណ ១០ ដង ពីប្រមាណ ៣,១១ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ១៩៩៨ ដល់ប្រមាណ ២៩,៦០ ប៊ីលានដុល្លារអាម៉េរិក នៅឆ្នាំ២០២២។ ជាមួយគ្នានេះ ផ.ស.ស. សម្រាប់មនុស្សម្នាក់ បានកើនឡើងរហូតដល់ ៧ ដង គឺពីប្រមាណ ២៥៣ ដុល្លារអាមេរិក ក្នុងឆ្នាំ១៩៩៨ ដល់ប្រមាណ ១ ៧៨៤ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២២ អត្រាភាពក្រីក្រធ្លាក់ចុះនៅក្រោម ១០% នៅមុនវិបត្តិជំងឺកូវីដ-១៩ និង គម្លាតវិសមភាពសង្គមកាន់តែរួមតូច រចនាសម្ព័ន្ធសេដ្ឋកិច្ចបានផ្លាស់ប្តូរពីសេដ្ឋកិច្ចពឹងផ្អែកជាចម្បងលើកសិកម្មប្រពៃណី ទៅជាសេដ្ឋកិច្ចពឹងលើឧស្សាហកម្ម និងសេវាកម្ម ដែលមានតម្លៃបន្ថែមខ្ពស់ជាងមុន។ ទន្ទឹមទៅនឹងការផ្សារភ្ជាប់កាន់តែខ្លាំងទៅនឹងខ្សែប្រវាក់តម្លៃ និង ខ្សែប្រវាក់ផ្គត់ផ្គង់ក្នុងតំបន់ និង សកល កម្ពុជាក៏សម្រេចបាននូវវឌ្ឍនភាពនៃការធ្វើពិពិធកម្មទំនិញ និងទីផ្សារនាំចេញ ដោយប្រមាណជា ១/៣ នៃរចនាសម្ព័ន្ធទំនិញនាំចេញបានផ្លាស់ប្តូរពីការពឹងផ្អែកខ្លាំងលើការនាំចេញផលិតផលកាត់ដេរ ដែលមានចំណែកប្រមាណជា ៩១% នៃការនាំចេញសរុប នាឆ្នាំ២០០០ មកត្រឹម ៦២% នាឆ្នាំ២០២២ ខណៈដែលផលិតផលឧស្សាហកម្មមិនមែនកាត់ដេរបានបង្កើនការរួមចំណែករបស់ខ្លួនក្នុងការនាំចេញសរុបពី ៩% មក ៣៨%។ ជាមួយគ្នានេះ កម្ពុជាក៏បានពង្រីកទីផ្សារនាំចេញរបស់ខ្លួនបន្ថែមទៅកាន់ប្រទេសផ្សេងៗ ក្នុងតំបន់អាស៊ានបូក ៣ ដោយកាត់បន្ថយជាបណ្តើរៗ នូវការពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើទីផ្សារសហរដ្ឋអាមេរិក និង អឺរ៉ុប។

ជាមួយនឹងកំណើនខ្ពស់ និង ពិពិធកម្មសេដ្ឋកិច្ច កម្ពុជាបានដាក់ចេញនូវមហិច្ឆតារបស់ខ្លួន នៅក្នុងដំណើរអភិវឌ្ឍន៍វែងឆ្ងាយ គឺការប្រែក្លាយទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ទោះជាយ៉ាងនេះក្តី វិបត្តិជំងឺកូវីដ-១៩ បានក្លាយជាវិញ្ញាសាជាក់ស្តែងមួយ សម្រាប់សាកល្បងភាពធន់នៃសង្គម សេដ្ឋកិច្ចកម្ពុជា សមត្ថភាពនៃប្រព័ន្ធសុខាភិបាល និងសមត្ថភាពធនធានរបស់កម្ពុជា ក្នុងការឆ្លើយតបនឹងវិបត្តិដែលមិនធ្លាប់មានពីមុនមក ទាំងទំហំ និង ទាំងជម្រៅនៃការប៉ះពាល់លើសង្គមសេដ្ឋកិច្ចកម្ពុជា។ ក្នុងស្ថានភាពនោះ កម្ពុជាត្រូវប្រយុទ្ធមិនគ្រាន់តែលើសមរភូមិសុខភាពសាធារណៈប៉ុណ្ណោះទេ ប៉ុន្តែត្រូវប្រយុទ្ធក្នុងសមរភូមិអប់រំគាំពារសង្គមហិរញ្ញវត្ថុក៏ដូចជាសេដ្ឋកិច្ចដោយរួមបញ្ចូលទាំងការរក្សាលំនឹងអាជីវកម្មលំនឹងជីវភាពប្រជាពលរដ្ឋនិងលំនឹងសតិអារម្មណ៍របស់ប្រជាជនជារួម។ ទោះបីស្ថិតក្នុងស្ថានភាពដ៏លំបាកយ៉ាងនេះក្តី ក្រោមការដឹកនាំដ៏ប៉ិនប្រសព្វ និងឈ្លាសវៃរបស់ **សម្តេចតេជោ** កម្ពុជា

បានយកឈ្នះលើសមរភូមិជំងឺកូវីដ-១៩ រក្សាបានលំនឹងសង្គម សេដ្ឋកិច្ច និងឈានទៅបើកប្រទេសទាំងស្រុងឡើងវិញ។

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី!**

ទោះបីជាកម្ពុជាបន្តទទួលរងនូវផលប៉ះទង្គិចពីវិបត្តិជំងឺកូវីដ-១៩ ហើយវិបត្តិផ្សេងៗទៀតក៏កំពុងបន្តកើតឡើង រាជរដ្ឋាភិបាលមិនបានបោះបង់ ឬ ផ្លាស់ប្តូរនូវទិសដៅអនុវត្តរយៈពេលវែងនោះទេ។ រាជរដ្ឋាភិបាលនៅតែរក្សាគោលដៅសម្រេចមហិច្ឆតារបស់ខ្លួនដដែល គឺកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់ នៅឆ្នាំ២០៣០ និង ចំណូលខ្ពស់ នៅឆ្នាំ២០៥០។ ក្នុងន័យនេះ ដោយឈរលើស្មារតី «រក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មី» និង «គិតគូរជាសកល និង អនុវត្តតាមបរិការណ៍ក្នុងប្រទេស (Think Globally and Act Locally)» រាជរដ្ឋាភិបាល នីតិកាលទី ៧ បានដាក់ចេញនូវ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និង ចីរភាព ព្រមទាំងកំណត់យកនូវអាទិភាពគន្លឹះចំនួន ៥៖ មនុស្ស ផ្លូវ ទឹក ភ្លើង និង បច្ចេកវិទ្យា ដែលត្រូវបានឆ្លុះបញ្ចាំងជាចម្បងតាមរយៈបញ្ចកោណយុទ្ធសាស្ត្រទាំង៥នៅក្នុងរចនាសម្ព័ន្ធនៃយុទ្ធសាស្ត្រទាំងមូល។យុទ្ធសាស្ត្របញ្ចកោណប្រកាន់យកទស្សនវិស័យវែងឆ្ងាយ ដោយកំណត់ទិសដៅអាទិភាព និង អនុវត្តជា ៥ ដំណាក់កាល ឈានឆ្ពោះទៅសម្រេចចក្ខុវិស័យវែងឆ្ងាយ ឈរលើបេសកកម្មជាប្រវត្តិសាស្ត្រចម្បងពីរ៖ (ទី១). ថែរក្សា និង ថែបំប៉នសុខសន្តិភាព ដែលសម្រេចបានមកដោយលំបាក ជាមួយនឹងការលះបង់មិនអាចកាត់ថ្លៃបាន និង ពូនជ្រំចលនការ នៃកំណើនសេដ្ឋកិច្ច និង ការអភិវឌ្ឍជារួម និង (ទី២). កសាង និង ពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ជំរុញសម្ទុះនៃការអភិវឌ្ឍប្រទេសជាតិ ឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

រាជរដ្ឋាភិបាលមិនឈប់ត្រឹមការដាក់ចេញនូវយុទ្ធសាស្ត្រប៉ុណ្ណោះទេ ប៉ុន្តែបានដាក់ចេញនូវកម្មវិធី យន្តការកែទម្រង់ និងវិធានការជាក់ស្តែងជាបន្តបន្ទាប់។ ក្នុងរយៈពេលជាង ២ ខែកន្លងទៅ រាជរដ្ឋាភិបាលបានដាក់ចេញជាបន្តបន្ទាប់នូវ «កម្មវិធីគោលនយោបាយអាទិភាព ៦» ក្នុងនោះកម្មវិធីចំនួន ៥ ត្រូវបានប្រកាស និងដាក់ឱ្យចាប់ផ្តើមអនុវត្តរួចហើយ រួមមាន៖ (ទី១). «យុទ្ធសាស្ត្រជាតិស្តីពីការអភិវឌ្ឍសេដ្ឋកិច្ចក្រៅប្រព័ន្ធ ឆ្នាំ២០២៣-២០២៨» (ទី២). «ការពង្រីកវិសាលភាពមូលនិធិសមធម៌សុខាភិបាលដល់គ្រួសារងាយរងហានិភ័យ» និង(ទី៣). «ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង បច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និង ងាយរងហានិភ័យនៅទូទាំងប្រទេស» ជាមួយនឹង «ការពង្រីកវិសាលភាពរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ដល់បុគ្គលស្វ័យនិយោជន៍ និង អ្នកក្នុងបន្ទុករបស់សមាជិក ប.ស.ស. ដោយផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត» (ទី៤). «កម្មវិធីហិរញ្ញប្បទានសំដៅលើកស្ទួយផលិតផលកសិកម្មរកទីផ្សារ និង រក្សាលំនឹងថ្លៃកសិផលសំខាន់ៗ ក្នុងកម្រិតសមរម្យ» និង (ទី៥). «ការដាក់ពង្រាយមន្ត្រីបច្ចេកទេសកសិកម្មទៅគ្រប់ឃុំ សង្កាត់ ដែលមានសកម្មភាពកសិកម្មនៅទូទាំងប្រទេស និង ការរៀបចំឱ្យមានសហគមន៍កសិកម្មបែបថ្មី»។

ក្នុងអំឡុងពេលនេះដែរ ក្នុងចំណោម «វិធានការគន្លឹះ ៥» ដែលមានចរិតជាការកែទម្រង់ស្ថាប័ន រាជរដ្ឋាភិបាលបានសម្រេចរៀបចំនូវគណៈកម្មាធិការជាតិ ៣ រួមមាន (១). គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ (២). គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យអប់រំ (៣). គណៈកម្មាធិការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងវិស័យសុខាភិបាល។ បន្ថែមលើនេះ រាជរដ្ឋាភិបាលក៏បានដាក់ចេញនូវការរៀបចំ និង កិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។

កាលពីសប្តាហ៍កន្លងទៅ នៅក្នុងវេទិការាជរដ្ឋាភិបាល ផ្នែកឯកជនលើកទី ១៩ ខ្ញុំបានសម្រេចដាក់ចេញនូវវិធានការមុតស្រួច ដែលមានចរិតជាការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលអាណត្តិថ្មី ដើម្បីជំរុញដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ច និង លើកកម្ពស់ភាពប្រកួតប្រជែងកម្ពុជា ក៏ដូចជាឆ្លើយតបនឹងកង្វល់របស់ផ្នែកឯកជន ដែលមានជិត ២០០ ដើម្បីកាត់បន្ថយថ្លៃធ្វើធុរកិច្ច និងការសម្រាលបន្ទុករបស់ប្រជាជនទូទៅ លុបបំបាត់ និង កាត់បន្ថយនីតិវិធីរដ្ឋបាលមិនចាំបាច់នានា ជួយសម្រួលដល់ធុរជន និង ប្រជាពលរដ្ឋក្នុងការបំពេញកាតព្វកិច្ចតម្រូវរបស់ច្បាប់ បង្កើនប្រសិទ្ធភាព នៃការផ្តល់សេវាសាធារណៈ និង វិធានការជាច្រើនផ្សេងទៀត។

ជាមួយនឹងការអនុវត្តកម្មវិធីគោលនយោបាយវិធានការគន្លឹះនិងវិធានការកែទម្រង់មុតស្រួចនានាដែលត្រូវបានដាក់ចេញកន្លងមកនិងវិធានការបុរេសកម្មផ្សេងៗ ក្នុងពេលខាងមុខ កម្ពុជារំពឹងថានឹងសម្រេចបានកំណើនសេដ្ឋកិច្ច ក្នុងអត្រា ៥,៦% នៅឆ្នាំ២០២៣ និងបន្តងើបកាន់តែលឿន ក្នុងអត្រា៦,៦%នៅឆ្នាំ២០២៤។ប្រាកដណាស់ថា ទស្សនវិស័យកំណើននេះក៏អាចប្រឈមនឹងហានិភ័យមួយចំនួន ក្នុងពេលដែលស្ថានភាពបច្ចុប្បន្ននៅមានភាពមិនប្រាកដប្រជាខ្ពស់នៅឡើយ។ ក្នុងន័យនេះ កម្ពុជាចាំបាច់ត្រូវប្រកាន់យកស្មារតីនៃ «ការកែទម្រង់ជាប្រចាំ និង បុរេសកម្មជានិច្ច» ដោយព្យាយាមកសាងឱ្យបាននូវភាពធន់ផង និង ជំរុញពិពិធកម្មសេដ្ឋកិច្ចផង។

- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី!**

សម្រាប់សន្និសីទយើងនៅពេលនេះ ខ្ញុំមានចំណាប់អារម្មណ៍ជាខ្លាំងលើកិច្ចពិភាក្សាទាំងបីវគ្គនៅថ្ងៃនេះ ដែលសុទ្ធតែជាប្រធានបទមានសារៈសំខាន់ ជាពិសេសផ្នែកគោលនយោបាយ សម្រាប់កម្ពុជាអាចត្រៀមខ្លួនឱ្យបានល្អ និង គ្រប់គ្រាន់ ដើម្បីសម្រេចបង្គោលចរឆ្នាំ ២០៣០ និង ឆ្នាំបន្តបន្ទាប់ខាងមុខទៀត។ ដូចបានបញ្ជាក់ខាងលើ សេដ្ឋកិច្ចកម្ពុជា គឺជាសេដ្ឋកិច្ចបើកចំហ ដូច្នេះការផ្លាស់ប្តូរជាវិជ្ជមាន និង អវិជ្ជមានពីកត្តាខាងក្រៅនឹងជះឥទ្ធិពលដោយផ្ទាល់ និង ប្រយោលមកលើសក្តានុពលកំណើនកម្ពុជារយៈពេលមធ្យម និង រយៈពេលវែង។ ដើម្បីជាការចូលរួមបំផុសគំនិតសម្រាប់ការពិភាក្សា ខ្ញុំសូមលើកនូវការសង្កេតមួយចំនួនពាក់ព័ន្ធនឹងការវិវត្ត នៃបរិការណ៍សកល ដូចខាងក្រោម៖

ទី១). ការប្រែប្រួលដ៏ជ្រាលជ្រៅមួយ នៃការផ្លាស់ប្តូរពីនិម្មាបនកម្មសេដ្ឋកិច្ច និង អភិបាលកិច្ចអន្តរជាតិលក្ខណៈឯកប៉ូល ទៅរកប្រព័ន្ធពហុប៉ូល ដែលកំពុងលេចចេញជារូបរាងបណ្តើរៗ

ទី២). ការចាប់ផ្តើមពឹងផ្អែកកាន់តែខ្លាំងឡើងលើសេដ្ឋកិច្ចក្នុងតំបន់ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ច នៅពេលដែលប្រទេសក្នុងតំបន់កាន់តែរីកចម្រើនឡើង និង សមាហរណកម្មកាន់តែស៊ីជម្រៅ ខណៈដែលសេដ្ឋកិច្ចធំៗសម្រេចបានកំណើនទាប

ទី៣). ការរីកចម្រើនផ្នែកឌីជីថលបន្តមានសន្ទុះខ្ពស់ ជាពិសេសបញ្ញាសិប្បនិម្មិត ដែលបើកលទ្ធភាពក្នុងការជំរុញផលិតភាពឱ្យមានសន្ទុះខ្ពស់ឡើង និង អាចកាត់បន្ថយរយៈពេល នៃការរៀនសូត្រ ព្រមទាំងអាចពង្រាយបានទូលាយក្នុងរយៈពេលខ្លី និង

ទី៤). ប្រភពហិរញ្ញប្បទានសម្រាប់ទ្រទ្រង់ការអភិវឌ្ឍ ក្នុងបរិការណ៍នៃការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ ជាពិសេសសម្រាប់ប្រទេសមានចំណូលមធ្យម មានទំហំមិនគ្រប់គ្រាន់ និង មិនមានការសម្របសម្រួលល្អរវាងតួអង្គពាក់ព័ន្ធ ទាំងពហុភាគី ទ្វេភាគី និង វិស័យឯកជន។

ក្នុងន័យនេះ ខ្ញុំចង់ឃើញសន្និសីទរបស់យើងនាថ្ងៃនេះ គឺដើរតួជាវេទិកានៃការផ្លោះប្តូរយោបល់ត្រង់ទៅត្រង់មក ប្រកបដោយស្មារតីស្ថាបនា និង ចូលរួមគិតគូរអនុវត្ត និង ទទួលខុសត្រូវរួមគ្នាលើជោគវាសនារបស់កម្ពុជា។ ទន្ទឹមនឹងនេះ ខ្ញុំក៏ចង់ឃើញផងដែរថា លទ្ធផលនៃការសិក្សារបស់វិទ្យាស្ថាន CDRI នាពេលបន្តបន្ទាប់ នឹងមិនគ្រាន់តែជាការសិក្សាស្រាវជ្រាវបង្កើនការយល់ដឹងប៉ុណ្ណោះទេ ថែមទាំងជាឯកសារចង្អុលទិសគន្លឹះ សម្រាប់ជាធាតុចូលដល់រាជរដ្ឋាភិបាល ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍នានា ក៏ដូចជាវិធានការគោលនយោបាយ ដើម្បីដំណោះស្រាយបញ្ហាប្រឈមទាំងឡាយដែលកំពុងកើតមាន និង នាពេលបន្តបន្ទាប់ រួមទាំងបញ្ហាប្រឈមនៅពេលដែលកម្ពុជារំពឹងថានឹងឆ្លងផុតពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួច នាឆ្នាំ២០២៧ ខាងមុខ ការពង្រឹង និង ការពង្រីកមូលដ្ឋានសេដ្ឋកិច្ចឱ្យបានរឹងមាំ និង មានពិពិធកម្មជាងមុន និង ការកសាងភាពធន់សង្គម សេដ្ឋកិច្ច ដើម្បីឈានឆ្ពោះទៅសម្រេចចក្ខុវិស័យរយៈពេលវែងរបស់កម្ពុជា។ ការចូលរួមរបស់ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី នៅថ្ងៃនេះ ពិតជាមានសារៈសំខាន់ ដែលបង្ហាញពីការលះបង់កម្លាំងកាយចិត្ត ដើម្បីអនាគតរបស់កម្ពុជា។

ខ្ញុំសង្ឃឹមជឿជាក់ថា សន្និសីទនាថ្ងៃនេះ នឹងប្រព្រឹត្តទៅដោយរលូន និងប្រកបដោយផ្លែផ្កា។ ខ្ញុំសូមលើកទឹកចិត្ត ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រីទាំងអស់ ចូលរួមឱ្យបានសកម្ម និងផុសផុល ក្នុងការពិភាក្សា ដើម្បីឱ្យសន្និសីទនាថ្ងៃនេះបញ្ចប់ទៅប្រកបដោយផ្លែផ្កា និង ទទួលបានធាតុចូលសំខាន់ៗ សម្រាប់ជាជំនួយដល់ការវិភាគ និង ការសន្និដ្ឋានរបស់វិទ្យាស្ថាន CDRI លើប្រធានបទដ៏មានសារៈសំខាន់ថ្ងៃនេះ។

ជាចុងបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឧកញ៉ា លោក លោកស្រី និង ភ្ញៀវកិត្តិយសទាំងអស់ ឱ្យទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច និង ជួបប្រទះនឹងពរ និង ពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និង បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០២៣ ចាប់ពីពេលនេះតទៅ៕

**សូមអរគុណ!**



រៀបចំអត្ថបទដោយៈ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.



# ផ្នែកទី ៤

# ទស្សនៈ និង មតិ

... ហើយការអភិវឌ្ឍ យើងខិតខំយករូបមន្ត
**PPP ភាពជាដៃគូនៃរដ្ឋ និងវិស័យឯកជន**
ដើម្បីអភិវឌ្ឍ រដ្ឋដើរតួនាទីកម្រិតណា
បើកច្រកឱ្យវិស័យឯកជនចូលរួមកម្រិតណា
ដើម្បីដើរតួនៅក្នុងការចូលរួមអភិវឌ្ឍ ...



*ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់*

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

*ថ្លែងក្នុងពិធីបើកការដ្ឋានសាងសង់ចំណតផែកុងតឺន័រទឹកជ្រៅ
ជំហានទី១ ខេត្តព្រះសីហនុ ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០២៣*





ការរៀបចំប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាល
បច្ចេកវិទ្យាព័ត៌មាន គឺជាការកែទម្រង់មួយដ៏សំខាន់
ក្នុងដំណើរឆ្ពោះទៅរកការកសាងរដ្ឋាភិបាល
សេដ្ឋកិច្ច និងសង្គមឌីជីថល។ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម
តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ១
បានអនុញ្ញាតឱ្យគ្រប់ក្រុមហ៊ុន សហគ្រាស
អាចចុះបញ្ជីជាកញ្ចប់ជាមួយនឹងក្រសួង ស្ថាប័ន ចំនួន ៣
រួមមាន៖ ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ
នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង
ក្រសួង ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
ព្រមទាំងអាចចុះបញ្ជីជាគម្រោងមានលក្ខណៈសម្បត្តិ
គ្រប់គ្រាន់ (Qualified Investment Project - QIP)
ជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។



*ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់*

## ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

*ថ្លែងក្នុងពិធីប្រកាសដាក់ឱ្យដំណើរការជាផ្លូវការ នូវប្រព័ន្ធចុះបញ្ជី
អាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ៣
ទីស្តីការ កសហវ. ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣*

នៅពេលទារកត្រូវបានចុះបញ្ជី
ក្នុងប្រព័ន្ធឌីជីថល គឺទិន្នន័យនោះ នឹងត្រូវបញ្ជូនភ្លាមៗ
ទៅកាន់អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មក្រសួងមហាផ្ទៃ ដើម្បី
ចេញលេខកូដអត្តសញ្ញាណទារក សម្រាប់ប្រើប្រាស់តាមតម្រូវការ ចាប់ពី
ពេលចុះបញ្ជីរហូតដល់មរណភាព។ ... ហើយជាមួយគ្នានេះ
នៅពេលដែលគ្រប់អាយុត្រូវធ្វើអត្តសញ្ញាណបណ្ណ
សញ្ជាតិខ្មែរ ឬលិខិតស្នាមផ្សេងៗ សាមីខ្លួនអាចប្រើប្រាស់លេខកូដនោះ
ដើម្បីស្នើសុំសេវាតាមប្រព័ន្ធអនឡាញបានតែម្តង។ ការសាកល្បងនេះ
ជាជំហ៊ានថ្មីមួយទៀត នៃកំណែទម្រង់ស្របតាមយុទ្ធសាស្ត្របញ្ចកោណ
របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់
សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។



*ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់*

**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

*ថ្លែងក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តជម្ពូវណ្ណារាមក្បាលទន្សោង ស្ថិតក្នុងភូមិក្បាលទន្សោង ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០២៤*





រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី ៧ ដែលមាន
**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
បានប្រកាសឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១
ដោយបានដាក់ចេញយុទ្ធសាស្ត្រ ដើម្បីកំណើន ការងារ សមធម៌
ប្រសិទ្ធភាព និងចីរភាព ព្រមទាំងបានកំណត់យក
អាទិភាពគន្លឹះ ៥ គឺមនុស្ស ផ្លូវ ទឹក ភ្លើង និងបច្ចេកវិទ្យា ជាពិសេស
បច្ចេកវិទ្យាឌីជីថល សម្រាប់ឆ្លើយតបទៅនឹងបដិវត្តឧស្សាហកម្មទី ៤
និងបរិវត្តកម្មឌីជីថល នៃសេដ្ឋកិច្ច និងសង្គម។ ទន្ទឹមនេះ ការគ្រប់គ្រង
និងការធ្វើទំនើបកម្ម នគរូបនីយកម្ម ជាមុំមួយនៃការអនុវត្ត
យុទ្ធសាស្ត្របញ្ចកោណ ដោយបន្តដំណើការកែទម្រង់ដីធ្លី
ជំរុញការចុះបញ្ជី និងការដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការ
ក្នុងគោលដៅគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យដីធ្លីឱ្យបានត្រឹមត្រូវ
កាត់បន្ថយវិវាទឱ្យកាន់តែមានប្រសិទ្ធភាព។

*ប្រសាសន៍ដ៏ខ្លង់ខ្លស់របស់*

**ឯកឧត្តម សាយ សំអាល់**

ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំ
ដែនដី នគរូបនីយកម្ម និងសំណង់

*ថ្លែងក្នុងពិធីចែកវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ
ជូនប្រជាពលរដ្ឋក្នុងភូមិព្រៃញាតិ ភូមិដូង ភូមិផ្លូវដំរី
ចំនួន ១,៧៧២ ក្បាលដី ក្នុងស្រុកគងពិសី
ខេត្តកំពង់ស្ពឺ ថ្ងៃទី១២ ខែមករា ឆ្នាំ២០២៤*



ក្រសួងកំពុងរៀបចំស្ថាប័នចំនួន ៨ បន្ថែមទៀត ឱ្យក្លាយជាអង្គភាពថវិកា នៅឆ្នាំ២០២៤ ដែលធ្វើឱ្យអង្គភាពថវិកាសរុបរបស់ក្រសួង រួមទាំងមន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍រាជធានី ខេត្ត កើនឡើងដល់ ៣៤ អង្គភាព។ កំណែទម្រង់នេះបង្ហាញពីការប្តេជ្ញាចិត្តចំពោះស្វ័យភាព និងការទទួលខុសត្រូវរបស់ស្ថាប័ន។ គោលដៅចម្បង គឺផ្តល់សិទ្ធិអំណាចដល់ស្ថាប័នទាំងនេះ ឱ្យក្លាយជាអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ នៅត្រឹមដំណាច់ឆ្នាំ២០២៤ ឬដើមឆ្នាំ២០២៥។.... ស្វ័យភាពត្រូវតែផ្សារភ្ជាប់ជាមួយនឹងការទទួលខុសត្រូវ ដែលក្នុងនោះក្រសួងនឹងរៀបចំកិច្ចសន្យាសមិទ្ធកម្មជាមួយអង្គភាពថវិកា ដែលមានសូចនាករសំខាន់ៗ សម្រាប់វាស់វែងការងាររបស់អង្គភាពថវិកាទាំងនេះ៕



*ប្រសាសន៍ដ៏ខ្ពង់ខ្ពស់របស់*

**ឯកឧត្តម ហែម វណ្ណឌី**

រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

*ថ្លែងក្នុងសិក្ខាសាលារយៈពេលពីរថ្ងៃស្តីពី "នីតិវិធីនៃការអនុវត្តថវិកាសមិទ្ធកម្ម" ដែលជាជំហានថ្មីមួយក្នុងការលើកកម្ពស់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់សេវាសាធារណៈរបស់ខ្លួន ខេត្តព្រះសីហនុ ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៣*

រៀបចំអត្ថបទដោយ៖ ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍ នៃ អ.គ.ហ.



# អគ្គលេខាធិការដ្ឋាន
# គណៈកម្មាធិការដឹកនាំការងារ
# កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## គណៈគ្រប់គ្រង៖

| | |
|---|---|
| រស់ សីលវ៉ា | អគ្គលេខាធិការ អ.គ.ហ. |
| បណ្ឌិត ហ៊ែល ចំរើន | អគ្គលេខាធិការរង អ.គ.ហ. |
| មាស សុខសេនសាន | អគ្គលេខាធិការរង អ.គ.ហ. |
| ប៉ែន ធីរុង្គ | អគ្គលេខាធិការរង អ.គ.ហ. |
| យ៉េត វីណែល | អគ្គលេខាធិការរង អ.គ.ហ. |
| អ៊ុង លុយណា | អគ្គលេខាធិការរង អ.គ.ហ. |
| ប៊ូ វង្សសុខា | អគ្គលេខាធិការរង អ.គ.ហ. |

## រៀបចំអត្ថបទដោយ៖

ផ្នែកអន្តរកែទម្រង់

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

ផ្នែកអនុវត្តថវិកា

ផ្នែកគោលនយោបាយ និងរៀបចំថវិកា

ផ្នែកចំណូលសារពើពន្ធ

ផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងត្រួតពិនិត្យនិងវាយតម្លៃ

## ការចូលរួមផ្សេងៗ៖

អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ

ធនាគារពិភពលោក (World Bank)

## នវានុវត្តន៍ និងកែសម្រួលដោយ៖

ផ្នែកស្រាវជ្រាវ និងនវានុវត្តន៍

# ១

## មករា ២០២៤

មិគសិរ-បុស្ស ឆ្នាំថោះ ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ៣១ | ១<br>៥ រោច | ២<br>៦ រោច | ៣<br>៧ រោច | ៤<br>៨ រោច | ៥<br>៩ រោច | ៦<br>១០ រោច |
| ៧<br>១១ រោច | ៨<br>១២ រោច | ៩<br>១៣ រោច ថ្ងៃកោរ | ១០<br>១៤ រោច | ១១<br>បុស្ស | ១២<br>២ កើត | ១៣<br>៣ កើត |
| ១៤<br>៤ កើត | ១៥<br>៥ កើត | ១៦<br>៦ កើត | ១៧<br>៧ កើត | ១៨<br>៨ កើត | ១៩<br>៩ កើត | ២០<br>១០ កើត |
| ២១<br>១១ កើត | ២២<br>១២ កើត | ២៣<br>១៣ កើត | ២៤<br>១៤ កើត ថ្ងៃកោរ | ២៥<br>១៥ កើត ពេញបូណ៌មី | ២៦<br>១ រោច | ២៧<br>២ រោច |
| ២៨<br>៣ រោច | ២៩<br>៤ រោច | ៣០<br>៥ រោច | ៣១<br>៦ រោច | ១<br>៧ រោច | ២<br>៨ រោច | ៣<br>៩ រោច |
| ៤<br>១៥ កើត | ៥<br>១១ រោច | ៦<br>១២ រោច | ៧<br>១៣ រោច | ៨<br>១៤ រោច ថ្ងៃកោរ | ៩<br>១៥ រោច | ១០<br>មាឃ |

១ : ទិវាចូលឆ្នាំសកល

៧ : ទិវាជ័យជម្នះលើរបបប្រល័យពូជសាសន៍

# ២

## កុម្ភៈ ២០២៤

បុស្ស-មាឃ ឆ្នាំថោះ ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៨<br>៣ រោច | ២៩<br>៤ រោច | ៣០<br>៥ រោច | ៣១<br>៦ រោច | ១<br>៧ រោច | ២<br>៨ រោច | ៣<br>៩ រោច |
| ៤<br>១០ រោច | ៥<br>១១ រោច | ៦<br>១២ រោច | ៧<br>១៣ រោច | ៨<br>១៤ រោច ថ្ងៃកោរ | ៩<br>១៥ រោច | ១០<br>មាឃ |
| ១១<br>២ កើត | ១២<br>៣ កើត | ១៣<br>៤ កើត | ១៤<br>៥ កើត | ១៥<br>៦ កើត | ១៦<br>៧ កើត | ១៧<br>៨ កើត |
| ១៨<br>៩ កើត | ១៩<br>១០ កើត | ២០<br>១១ កើត | ២១<br>១២ កើត | ២២<br>១៣ កើត | ២៣<br>១៤ កើត ថ្ងៃកោរ | ២៤<br>១៥ កើត ពេញបូណ៌មី |
| ២៥<br>១ រោច | ២៦<br>២ រោច | ២៧<br>៣ រោច | ២៨<br>៤ រោច | ២៩<br>៥ រោច | ១<br>៦ រោច | ២<br>៧ រោច |
| ៣<br>៨ រោច | ៤<br>៩ រោច | ៥<br>១០ រោច | ៦<br>១១ រោច | ៧<br>១២ រោច | ៨<br>១៣ រោច ថ្ងៃកោរ | ៩<br>១៤ រោច |

៣ : ថ្ងៃសែនដកជើងធូប

៩ : ថ្ងៃសែនចូលឆ្នាំចិន

១០ : ចូលឆ្នាំចិន

១១ : ចូលឆ្នាំចិន

១២ : ចូលឆ្នាំចិន

១៤ : ថ្ងៃបុណ្យនៃសេចក្តីស្រលាញ់

២១ : ទិវាជាតិសុខភាពមាតា និងទារក

២៤ : ទិវាជាតិយល់ដឹងពីមីន

ពិធីបុណ្យមាឃបូជា

ហែអ្នកតាចិន

## ៣

# មីនា ២០២៤

មាឃ-ផល្គុន ឆ្នាំថោះ

ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៥ ១ រោច | ២៦ ២ រោច | ២៧ ៣ រោច | ២៨ ៤ រោច | ២៩ ៥ រោច | ១ ៦ រោច | ២ ៧ រោច |
| ៣ ៨ រោច | ៤ ៩ រោច | ៥ ១០ រោច | ៦ ១១ រោច | ៧ ១២ រោច | ៨ ១៣ រោច ថ្ងៃកោរ | ៩ ១៤ រោច |
| ១០ ផល្គុន | ១១ ២ កើត | ១២ ៣ កើត | ១៣ ៤ កើត | ១៤ ៥ កើត | ១៥ ៦ កើត | ១៦ ៧ កើត |
| ១៧ ៨ កើត | ១៨ ៩ កើត | ១៩ ១០ កើត | ២០ ១១ កើត | ២១ ១២ កើត | ២២ ១៣ កើត | ២៣ ១៤ កើត ថ្ងៃកោរ |
| ២៤ ១៥ កើតពេញបូណ៌មី | ២៥ ១ រោច | ២៦ ២ រោច | ២៧ ៣ រោច | ២៨ ៤ រោច | ២៩ ៥ រោច | ៣០ ៦ រោច |
| ៣១ ៧ រោច | ១ ៨ រោច | ២ ៩ រោច | ៣ ១០ រោច | ៤ ១១ រោច | ៥ ១២ រោច | ៦ ១៣ រោច |

៣ : ទិវាវប្បធម៌ជាតិ

៤ : ទិវានយោបាយទឹក

៨ : ទិវានារីអន្តរជាតិ

២២ : ទិវាពិភពលោកទឹក និងឧតុនិយម

២៤ : ទិវាពិភពលោកកំចាត់ជម្ងឺរបេង

២៧ : ទិវាជាតិសហគ្រាសធុនមីក្រូ តូច និងមធ្យម

## ៤

# មេសា ២០២៤

ផល្គុន-ចេត្រ ឆ្នាំរោង

ព.ស. ២៥៦៧

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ៣១ ៧ រោច | ១ ៨ រោច | ២ ៩ រោច | ៣ ១០ រោច | ៤ ១១ រោច | ៥ ១២ រោច | ៦ ១៣ រោច |
| ៧ ១៤ រោច ថ្ងៃកោរ | ៨ ១៥ រោច | ៩ ចេត្រ | ១០ ២ កើត | ១១ ៣ កើត | ១២ ៤ កើត | ១៣ ៥ កើត |
| ១៤ ៦ កើត | ១៥ ៧ កើត | ១៦ ៨ កើត | ១៧ ៩ កើត | ១៨ ១០ កើត | ១៩ ១១ កើត | ២០ ១២ កើត |
| ២១ ១៣ កើត | ២២ ១៤ កើត ថ្ងៃកោរ | ២៣ ១៥ កើត ពេញបូណ៌មី | ២៤ ១ រោច | ២៥ ២ រោច | ២៦ ៣ រោច | ២៧ ៤ រោច |
| ២៨ ៥ រោច | ២៩ ៦ រោច | ៣០ ៧ រោច | ១ ៨ រោច | ២ ៩ រោច | ៣ ១០ រោច | ៤ ១១ រោច |
| ៥ ១២ រោច | ៦ ១៣ រោច ថ្ងៃកោរ | ៧ ១៤ រោច | ៨ ពិសាខ | ៩ ២ កើត | ១០ ៣ កើត | ១១ ៤ កើត |

៤ : ឆេងម៉េង

៧ : ទិវាសុខភាពពិភពលោក

១៣ : ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ
មហាសង្ក្រាន្ត ម៉ោង ២២:២៤

១៤ : ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ វិរៈវ័នបត

១៥ : ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ វិរៈវ័នបត

១៦ : ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ថ្ងៃឡើងស័ក

៣០ : កម្ពុជាចូលជាសមាជិកអាស៊ាន

# ៥

## ឧសភា ២០២៤

ចេត្រ-ពិសាខ ឆ្នាំរោង

ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៨ ៥ រោច | ២៩ ៦ រោច | ៣០ ៧ រោច | ១ ៨ រោច | ២ ៩ រោច | ៣ ១០ រោច | ៤ ១១ រោច |
| ៥ ១២ រោច | ៦ ១៣ រោច ថ្ងៃកោរ | ៧ ១៤ រោច | ៨ ពិសាខ | ៩ ២ កើត | ១០ ៣ កើត | ១១ ៤ កើត |
| ១២ ៥ កើត | ១៣ ៦ កើត | ១៤ ៧ កើត | ១៥ ៨ កើត | ១៦ ៩ កើត | ១៧ ១០ កើត | ១៨ ១១ កើត |
| ១៩ ១២ កើត | ២០ ១៣ កើត | ២១ ១៤ កើត ថ្ងៃកោរ | ២២ ១៥ កើត ពេញបូណ៌មី | ២៣ ព.ស. ២៥៦៨ | ២៤ ២ រោច | ២៥ ៣ រោច |
| ២៦ ៤ រោច | ២៧ ៥ រោច | ២៨ ៦ រោច | ២៩ ៧ រោច | ៣០ ៨ រោច | ៣១ ៩ រោច | ១ ១០ រោច |
| ២ ១១ រោច | ៣ ១២ រោច | ៤ ១៣ រោច | ៥ ១៤ រោច ថ្ងៃកោរ | ៦ ១៥ រោច | ៧ ជេស្ឋ | ៨ ២ កើត |

១ : ទិវាពលកម្មអន្តរជាតិ

៣ : ទិវាសេរីភាពសារព័ត៌មានពិភពលោក

៨ : ទិវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម

១២ : ទិវាអ្នកម្តាយ

១៤ : ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទព្រះសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

១៥ : ទិវាអន្តរជាតិនៃគ្រួសារ

១៦ : កំណើតនគរបាលជាតិ

២០ : ទិវាជាតិនៃការចងចាំ

២២ : ពិធីបុណ្យវិសាខបូជា

២៦ : ព្រះរាជពិធីច្រត់ព្រះនង្គ័ល

៣១ : ទិវាពិភពលោកគ្មានថ្នាំជក់

# ៦

## មិថុនា ២០២៤

ពិសាខ-ជេស្ឋ ឆ្នាំរោង

ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៦ ៤ រោច | ២៧ ៥ រោច | ២៨ ៦ រោច | ២៩ ៧ រោច | ៣០ ៨ រោច | ៣១ ៩ រោច | ១ ១០ រោច |
| ២ ១១ រោច | ៣ ១២ រោច | ៤ ១៣ រោច | ៥ ១៤ រោច ថ្ងៃកោរ | ៦ ១៥ រោច | ៧ ជេស្ឋ | ៨ ២ កើត |
| ៩ ៣ កើត | ១០ ៤ កើត | ១១ ៥ កើត | ១២ ៦ កើត | ១៣ ៧ កើត | ១៤ ៨ កើត | ១៥ ៩ កើត |
| ១៦ ១០ កើត | ១៧ ១១ កើត | ១៨ ១២ កើត | ១៩ ១៣ កើត | ២០ ១៤ កើត ថ្ងៃកោរ | ២១ ១៥ កើត ពេញបូណ៌មី | ២២ ១ រោច |
| ២៣ ២ រោច | ២៤ ៣ រោច | ២៥ ៤ រោច | ២៦ ៥ រោច | ២៧ ៦ រោច | ២៨ ៧ រោច | ២៩ ៨ រោច |
| ៣០ ៩ រោច | ១ ១០ រោច | ២ ១១ រោច | ៣ ១២ រោច | ៤ ១៣ រោច ថ្ងៃកោរ | ៥ ១៤ រោច | ៦ អាសាឍ |

១ : ទិវាកុមារអន្តរជាតិ

៥ : ទិវាបរិស្ថានជាតិ និងបរិស្ថានពិភពលោក

១០ : សែនទំចាំង

១២ : ទិវាពិភពលោកប្រឆាំងពលកម្មកុមារ

១៥ : តុលាការយុត្តិធម៌អន្តរជាតិក្រុងឡាអេ សម្រេចឱ្យកម្ពុជាជាម្ចាស់កម្មសិទ្ធិ លើប្រាសាទព្រះវិហារ

១៦ : ទិវាលោកឪពុក

១៨ : ព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គល

២៦ : ទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

# ៧ កក្កដា ២០២៤

ជេស្ឋ-អាសាឍ ឆ្នាំរោង ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គារ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ៣០ ៩ រោច | ១ ១០ រោច | ២ ១១ រោច | ៣ ១២ រោច | ៤ ១៣ រោច ថ្ងៃកោរ | ៥ ១៤ រោច | ៦ អាសាឍ |
| ៧ ២ កើត | ៨ ៣ កើត | ៩ ៤ កើត | ១០ ៥ កើត | ១១ ៦ កើត | ១២ ៧ កើត | ១៣ ៨ កើត |
| ១៤ ៩ កើត | ១៥ ១០ កើត | ១៦ ១១ កើត | ១៧ ១២ កើត | ១៨ ១៣ កើត | ១៩ ១៤ កើត ថ្ងៃកោរ | ២០ ១៥ កើត ពេញបូណ៌មី |
| ២១ ១ រោច | ២២ ២ រោច | ២៣ ៣ រោច | ២៤ ៤ រោច | ២៥ ៥ រោច | ២៦ ៦ រោច | ២៧ ៧ រោច |
| ២៨ ៨ រោច | ២៩ ៩ រោច | ៣០ ១០ រោច | ៣១ ១១ រោច | ១ ១២ រោច | ២ ១៣ រោច | ៣ ១៤ រោច ថ្ងៃកោរ |
| ៤ ១៥ រោច | ៥ ស្រាពណ៍ | ៦ ២ កើត | ៧ ៣ កើត | ៨ ៤ កើត | ៩ ៥ កើត | ១០ ៦ កើត |

១ : ទិវាមច្ឆាជាតិ

៣ : កម្ពុជាចូលជាសមាជិកអង្គការយូណេស្កូ

៧ : ប្រាសាទព្រះវិហារ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ

៨ : ទំបន់ប្រាសាទសំបូរព្រៃគុក ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ

៩ : រុក្ខទិវា

១១ : ទិវាប្រជាជនពិភពលោក

១៣ : ពិធីសិតទៀនព្រះវស្សា

១៩ : បំបួសនាគខ្នាន

២១ : ចូលព្រះវស្សា

៣១ : សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ត្រូវបានចុះក្នុងបញ្ជីស្មារតីចងចាំ នៃពិភពលោករបស់យូណេស្កូ

# ៨ សីហា ២០២៤

អាសាឍ-ស្រាពណ៍ ឆ្នាំរោង ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គារ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៨ ៨ រោច | ២៩ ៩ រោច | ៣០ ១០ រោច | ៣១ ១១ រោច | ១ ១២ រោច | ២ ១៣ រោច | ៣ ១៤ រោច ថ្ងៃកោរ |
| ៤ ១៥ រោច | ៥ ស្រាពណ៍ | ៦ ២ កើត | ៧ ៣ កើត | ៨ ៤ កើត | ៩ ៥ កើត | ១០ ៦ កើត |
| ១១ ៧ កើត | ១២ ៨ កើត | ១៣ ៩ កើត | ១៤ ១០ កើត | ១៥ ១១ កើត | ១៦ ១២ កើត | ១៧ ១៣ កើត |
| ១៨ ១៤ កើត ថ្ងៃកោរ | ១៩ ១៥ កើត ពេញបូណ៌មី | ២០ ១ រោច | ២១ ២ រោច | ២២ ៣ រោច | ២៣ ៤ រោច | ២៤ ៥ រោច |
| ២៥ ៦ រោច | ២៦ ៧ រោច | ២៧ ៨ រោច | ២៨ ៩ រោច | ២៩ ១០ រោច | ៣០ ១១ រោច | ៣១ ១២ រោច |
| ១ ១៣ រោច ថ្ងៃកោរ | ២ ១៤ រោច | ៣ ភទ្របទ | ៤ ២ កើត | ៥ ៣ កើត | ៦ ៤ កើត | ៧ ៥ កើត |

១២ : ទិវាយុវជនអន្តរជាតិ

១៨ : សែនក្បាលទឹក

## ៩ កញ្ញា ២០២៤

ស្រាពណ៍-ភទ្របទ ឆ្នាំរោង

ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ១ ១៣ រោច ថ្ងៃកោរ | ២ ១៤ រោច | ៣ ភទ្របទ | ៤ ២ កើត | ៥ ៣ កើត | ៦ ៤ កើត | ៧ ៥ កើត |
| ៨ ៦ កើត | ៩ ៧ កើត | ១០ ៨ កើត | ១១ ៩ កើត | ១២ ១០ កើត | ១៣ ១១ កើត | ១៤ ១២ កើត |
| ១៥ ១៣ កើត | ១៦ ១៤ កើត ថ្ងៃកោរ | ១៧ ១៥ កើត ពេញបូណ៌មី | ១៨ ១ រោច | ១៩ ២ រោច | ២០ ៣ រោច | ២១ ៤ រោច |
| ២២ ៥ រោច | ២៣ ៦ រោច | ២៤ ៧ រោច | ២៥ ៨ រោច | ២៦ ៩ រោច | ២៧ ១០ រោច | ២៨ ១១ រោច |
| ២៩ ១២ រោច | ៣០ ១៣ រោច | ១ ១៤ រោច ថ្ងៃកោរ | ២ ១៥ រោច | ៣ អស្សុជ | ៤ ២ កើត | ៥ ៣ កើត |
| ៦ ៤ កើត | ៧ ៥ កើត | ៨ ៦ កើត | ៩ ៧ កើត | ១០ ៨ កើត | ១១ ៩ កើត | ១២ ១០ កើត |

៨ : ទិវាអក្ខរកម្មអន្តរជាតិ

១៦ : ទិវាអូហ្សូនបរិស្ថានអន្តរជាតិ

១៧ : តំបន់ប្រាសាទកោះកេរ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោករបស់អង្គការយូណេស្កូ, សែនលោកខែ

១៨ : បិណ្ឌ ១ ១៩ : បិណ្ឌ ២ ២០ : បិណ្ឌ ៣

២១ : ទិវាសន្តិភាពអន្តរជាតិ, បិណ្ឌ ៤

២២ : បិណ្ឌ ៥ ២៣ : បិណ្ឌ ៦

២៤ : ទិវាប្រកាសរដ្ឋធម្មនុញ្ញ, បិណ្ឌ ៧

២៥ : បិណ្ឌ ៨ ២៦ : បិណ្ឌ ៩

២៧ : ទិវាទេសចរណ៍ពិភពលោក, បិណ្ឌ ១០

២៨ : បិណ្ឌ ១១ ២៩ : បិណ្ឌ ១២

៣០ : បិណ្ឌ ៣

## ១០ តុលា ២០២៤

ភទ្របទ-អស្សុជ ឆ្នាំរោង

ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៩ ១២ រោច | ៣០ ១៣ រោច | ១ ១៤ រោច ថ្ងៃកោរ | ២ ១៥ រោច | ៣ អស្សុជ | ៤ ២ កើត | ៥ ៣ កើត |
| ៦ ៤ កើត | ៧ ៥ កើត | ៨ ៦ កើត | ៩ ៧ កើត | ១០ ៨ កើត | ១១ ៩ កើត | ១២ ១០ កើត |
| ១៣ ១១ កើត | ១៤ ១២ កើត | ១៥ ១៣ កើត | ១៦ ១៤ កើត ថ្ងៃកោរ | ១៧ ១៥ កើត ពេញបូណ៌មី | ១៨ ១ រោច | ១៩ ២ រោច |
| ២០ ៣ រោច | ២១ ៤ រោច | ២២ ៥ រោច | ២៣ ៦ រោច | ២៤ ៧ រោច | ២៥ ៨ រោច | ២៦ ៩ រោច |
| ២៧ ១០ រោច | ២៨ ១១ រោច | ២៩ ១២ រោច | ៣០ ១៣ រោច ថ្ងៃកោរ | ៣១ ១៤ រោច | ១ កត្តិក | ២ ២ កើត |
| ៣ ៣ កើត | ៤ ៤ កើត | ៥ ៥ កើត | ៦ ៦ កើត | ៧ ៧ កើត | ៨ ៨ កើត | ៩ ៩ កើត |

១ : ពិធីបុណ្យភ្ជុំបិណ្ឌ, ទិវាមនុស្សចាស់អន្តរជាតិ

២ : ពិធីបុណ្យភ្ជុំបិណ្ឌ ៣ : ពិធីបុណ្យភ្ជុំបិណ្ឌ

៥ : ទិវាគ្រូបង្រៀនពិភពលោក

១៥ : ទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ

១៧ : ចេញព្រះវស្សា ១៨ : កឋិនកាល

២៣ : ទិវារំលឹកខួបនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស

២៩ : ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

៣១ : បុណ្យខ្មោចហាឡូវីន

# ១១ វិច្ឆិកា ២០២៤

កត្តិក-កត្តិក ឆ្នាំរោង

ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ២៧ ១០ រោច | ២៨ ១១ រោច | ២៩ ១២ រោច | ៣០ ១៣ រោច ថ្ងៃកោរ | ៣១ ១៤ រោច | ១ កត្តិក | ២ ២ កើត |
| ៣ ៣ កើត | ៤ ៤ កើត | ៥ ៥ កើត | ៦ ៦ កើត | ៧ ៧ កើត | ៨ ៨ កើត | ៩ ៩ កើត |
| ១០ ១០ កើត | ១១ ១១ កើត | ១២ ១២ កើត | ១៣ ១៣ កើត | ១៤ ១៤ កើត ថ្ងៃកោរ | ១៥ ១៥ កើត ពេញបូណ៌មី | ១៦ ១ រោច |
| ១៧ ២ រោច | ១៨ ៣ រោច | ១៩ ៤ រោច | ២០ ៥ រោច | ២១ ៦ រោច | ២២ ៧ រោច | ២៣ ៨ រោច |
| ២៤ ៩ រោច | ២៥ ១០ រោច | ២៦ ១១ រោច | ២៧ ១២ រោច | ២៨ ១៣ រោច | ២៩ ១៤ រោច ថ្ងៃកោរ | ៣០ ១៥ រោច |
| ១ មិគសិរ | ២ ២ កើត | ៣ ៣ កើត | ៤ ៤ កើត | ៥ ៥ កើត | ៦ ៦ កើត | ៧ ៧ កើត |

- ៧ : របាំព្រះរាជទ្រព្យ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌
- ៩ : ពិធីបុណ្យឯករាជ្យជាតិ
- ១៤ : ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ
- ១៥ : ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ
- ១៦ : ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ
- ២៣ : ទិវាអនាម័យបរិស្ថានជាតិ
- ២៥ : ល្ខោនស្រមោលស្បែក ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ
- ២៨ : ល្ខោនខោល ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ
- ៣០ : ចាប៉ីដងវែង ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិ

# ១២ ធ្នូ ២០២៤

មិគសិរ-បុស្ស ឆ្នាំរោង

ព.ស. ២៥៦៨

| អាទិ | ចន្ទ | អង្គ | ពុធ | ព្រហ | សុក្រ | សៅរ៍ |
|---|---|---|---|---|---|---|
| ១ មិគសិរ | ២ ២ កើត | ៣ ៣ កើត | ៤ ៤ កើត | ៥ ៥ កើត | ៦ ៦ កើត | ៧ ៧ កើត |
| ៨ ៨ កើត | ៩ ៩ កើត | ១០ ១០ កើត | ១១ ១១ កើត | ១២ ១២ កើត | ១៣ ១៣ កើត | ១៤ ១៤ កើត ថ្ងៃកោរ |
| ១៥ ១៥ កើតពេញបូណ៌មី | ១៦ ១ រោច | ១៧ ២ រោច | ១៨ ៣ រោច | ១៩ ៤ រោច | ២០ ៥ រោច | ២១ ៦ រោច |
| ២២ ៧ រោច | ២៣ ៨ រោច | ២៤ ៩ រោច | ២៥ ១០ រោច | ២៦ ១១ រោច | ២៧ ១២ កើត | ២៨ ១៣ រោច ថ្ងៃកោរ |
| ២៩ ១៤ រោច | ៣០ បុស្ស | ៣១ ២ កើត | ១ | ២ | ៣ | ៤ |
| ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ |

- ១ : ទិវាពិភពលោកប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍
- ២ : ល្បែងទាញព្រ័ត្រ ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោក
- ៣ : ទិវាជនពិការពិភពលោក
- ៧ : ទិវាជាតិអ្នកនិពន្ធ
- ៩ : ទិវាប្រយុទ្ធប្រឆាំងអំពើពុករលួយ
- ១០ : ទិវាសិទ្ធិមនុស្សអន្តរជាតិ
- ១២ : ទិវាជាតិប្រឆាំងការជួញដូរមនុស្ស
- ១៤ : អង្គរ ត្រូវបានបញ្ចូលក្នុងបញ្ជីបេតិកភណ្ឌពិភពលោក, កម្ពុជាចូលជាសមាជិកអង្គការសហប្រជាជាតិ
- ២១ : សែនទំអ៊ី
- ២៥ : បុណ្យគ្រិស្តម៉ាស
- ២៩ : ទិវាសន្តិភាពនៅកម្ពុជា

ប្រតិទិនខ្មែរឆ្នាំ២០២៤




ទីស្ដីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ,
ផ្លូវលេខ ៩២, សង្កាត់វត្តភ្នំ, ខណ្ឌដូនពេញ,
រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។

www.pfm.gov.kh

(+៨៥៥) ៨៥ ៧៧៧ ៩២៤

gsc@pfm.gov.kh

www.facebook.com/gscpfm

ទាញយកព្រឹត្តិបត្រ